ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍
# ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា
# ប្រចាំឆ្នាំ២០២៥



ស័ក្តិសិទ្ធភាព នវានុវត្តន៍ និងបរិយាបន្ន

# អារម្ភកថា

ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុបានឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានឆ្លងកាត់ឧបសគ្គ និងការផ្លាស់ប្តូរជាច្រើនដំណាក់កាលក្នុងការកសាងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុដ៏ទំនើប និងកាន់តែមានភាពប្រសើរជាងមុន តាមរយៈការដាក់ចេញក្របខណ្ឌបទប្បញ្ញត្តិគ្របដណ្តប់បានទូលំទូលាយ ការកើនឡើងនូវផលិតផល និងសេវាធនាគារអនុលោមតាមស្តង់ដារអន្តរជាតិ។ ស្របតាមការវិវត្តរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីរួមចំណែកសម្រេចបាននូវយុទ្ធសាស្ត្ររយៈពេលវែងរបស់រាជរដ្ឋាភិបាលដែលចែងនៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។ បច្ចុប្បន្ន ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រដល់សកម្មភាពពាណិជ្ជកម្មក្នុងសេដ្ឋកិច្ចឌីជីថល លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងបានជំរុញបរិយាបន្នហិរញ្ញវត្ថុតាមរយៈការធ្វើឱ្យការទូទាត់កាន់តែមានភាពងាយស្រួល សុវត្ថិភាពខ្ពស់ចំណាយទាប និងអាចធ្វើប្រតិបត្តិការឆ្លងពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែង ការដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួមកាលពីពាក់កណ្តាលឆ្នាំ២០២៤ បានសម្រួល និងកាត់បន្ថយភាពស្មុគស្មាញដល់សមាជិកប្រព័ន្ធក្នុងការតភ្ជាប់ និងអាចគ្រប់គ្រងប្រព័ន្ធបានដោយងាយស្រួល។ ជាមួយគ្នានេះ ប្រព័ន្ធទូទាត់សងប្រាក់ក៏ត្រូវបានតភ្ជាប់ជាមួយបណ្តាប្រទេសជាច្រើនក្នុងតំបន់ ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងដែន និងក្នុងគោលដៅលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ គាំទ្រដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ និងអន្តរជាតិ។

ទន្ទឹមនឹងនោះ ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាក៏បានផ្តល់ឱកាសដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អភិវឌ្ឍ និងដាក់ចេញនូវផលិតផលនិងសេវាហិរញ្ញវត្ថុប្រកបដោយនវានុវត្តន៍ជាច្រើននៅលើទីផ្សារ។ ការដាក់ឱ្យប្រើប្រាស់សេវាធនាគារតាមទូរស័ព្ទចល័ត បានផ្តល់លទ្ធភាពឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបែបឌីជីថលដោយខ្លួនឯងបានតាមរយៈសេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត និងសេវាទូទាត់ចល័ត ជាពិសេសការទូទាត់តាមខេអេចឃ្យូអរកូតដែលជាមធ្យោបាយដ៏ពេញនិយមនាពេលបច្ចុប្បន្ន។ ក្នុងឆ្នាំ២០២៥ ចំនួនប្រតិបត្តិការ និងទំហំប្រាក់នៃការទូទាត់សងប្រាក់ឌីជីថលបានកើនឡើង ៦៥% និង ១៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២៤ ហើយទំហំប្រាក់ស្មើនឹងប្រមាណ ១៦ ដង នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។

ស្របពេលដែលនិន្នាការនៃការទូទាត់តាមប្រព័ន្ធឌីជីថលមានការកើនឡើង ការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ប្រកបដោយនវានុវត្តន៍ ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិសមស្របសម្រាប់គ្រប់គ្រងនិងជំរុញការអភិវឌ្ឍក្នុងវិស័យ ជាកត្តាចាំបាច់ដើម្បីធានាថាប្រព័ន្ធទូទាត់បានរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រកាសមួយចំនួន និងកំពុងបន្តរៀបចំប្រកាសបន្ថែមទៀតពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ សេវាទូទាត់ ឧបករណ៍ទូទាត់ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ក្នុងគោលដៅពង្រឹងសុវត្ថិភាព ប្រសិទ្ធភាព និងជំរុញនវានុវត្តន៍។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំសេចក្តីព្រាង

ឯកសារស្តីពី ផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ ក្នុងគោលដៅពង្រឹងបន្ថែមលើប្រតិបត្តិការប្រចាំថ្ងៃនៃដំណើរការរបស់ប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីទប់ទល់នឹងហានិភ័យដែលអាចបង្កឱ្យមានការរំខានយ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធទូទាត់ ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល។ ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថលជាផ្នែកមួយដ៏សំខាន់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីជំរុញការទទួលយក និងប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលប្រកបដោយសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងហិរញ្ញវត្ថុឌីជីថលដល់សាធារណជននៅតាមរាជធានី-ខេត្ត ដើម្បីឱ្យជ្រួតជ្រាបពីនីតិវិធីក្នុងការប្រើប្រាស់សេវាទូទាត់ឌីជីថល និងការបង្កាទប់ស្កាត់ការបន្លំឆបោក។ ការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ ដើម្បីធានានិរន្តរភាព និងស្ថិរភាពនៃកិច្ចដំណើរការប្រព័ន្ធទូទាត់សងប្រាក់ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ក៏ត្រូវបានបន្តពង្រឹងជាប្រចាំដោយអនុលោមតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ដែលជាគោលការណ៍ស្តង់ដារដែលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ។

សមិទ្ធផលសម្រេចបានខាងលើ ទទួលបានលទ្ធផលជាទីមោទនៈ ដែលឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដាក់ចេញគោលនយោបាយ និងបទប្បញ្ញត្តិ ព្រមទាំងអនុវត្តការត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួន ដែលគាំទ្រនិងជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាព និងនវានុវត្តន៍។ លើសពីនេះ ស្ថិតក្នុងយុគសម័យឌីជីថល ការអភិវឌ្ឍទាំងនេះក៏មិនអាចខ្វះបាននូវកិច្ចសហការល្អពីអាជ្ញាធរពាក់ព័ន្ធក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ ដើម្បីគាំទ្រឱ្យប្រព័ន្ធទូទាត់សងប្រាក់ដំណើរការដោយពិលាស និងមានប្រសិទ្ធភាព។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់ការបំពេញភារកិច្ចរបស់មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដែលបានរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើនជាលំដាប់។ ខ្ញុំក៏សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានាដែលបានផ្តល់កិច្ចសហការល្អ និងជិតស្និទ្ធនាពេលកន្លងមក។ ខ្ញុំមានសេចក្តីជឿជាក់យ៉ាងមុតមាំថា របាយការណ៍ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាប្រចាំឆ្នាំ២០២៥ នេះ នឹងក្លាយជាឯកសារដ៏មានតម្លៃសម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ និងជាព័ត៌មានដ៏មានអត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធស្វែងយល់អំពីដំណើរការ តួនាទី និងកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអភិវឌ្ឍ និងលើកកម្ពស់ប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីបម្រើផលប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាទាំងមូលឱ្យកាន់តែប្រសើរឡើង។

**ទេសាភិបាល**

**ជា សិរី**

# មាតិកា


**អារម្ភកថា** ... i

**បញ្ជីក្រាហ្វ តារាង និងប្រអប់** ... v

**អក្សរកាត់** ... vii

**បរិយាយសង្ខេប** ... ix

**ស្ថិតិអំពីស្ថានភាពសេវាទូទាត់សងប្រាក់** ... xiii

**១. ទិដ្ឋភាពទូទៅនៃប្រព័ន្ធទូទាត់សងប្រាក់** ... **១**

*១. ១. ទិដ្ឋភាពទូទៅ* ... ១

*១. ២. ក្របខណ្ឌបទប្បញ្ញត្តិ* ... ១

*១. ៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់* ... ៣

*១. ៤. សេវាទូទាត់សងប្រាក់* ... ៥

**២. ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន** ... **៧**

*២. ១. កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនទ្វេភាគី* ... ៧

*២. ២. កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនពហុភាគី* ... ១០

*២. ៣. វឌ្ឍនភាពនៃការផ្ទេរប្រាក់ឆ្លងដែន* ... ១១

*២. ៤. កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្មឆ្លងដែន* ... ១៣

*២. ៥. កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនជាមួយក្រុមហ៊ុនបណ្ដាញបណ្ណទូទាត់អន្តរជាតិ* ... ១៥

**៣. បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍** ... **១៨**

*៣. ១. ទិដ្ឋភាពទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ* ... ១៨

*៣. ២. នវានុវត្តន៍ឌីជីថល* ... ១៩

**៤. ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់ ............ ២២**

*៤. ១. ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់* ........................................................ ២២

*៤. ២. ការត្រួតពិនិត្យសេវាទូទាត់សងប្រាក់* ........................................................ ៣៣

**៥. ចំណេះដឹងហិរញ្ញវត្ថុឌីជីថល ........................................................ ៤១**

*៥. ១. កិច្ចការពារអតិថិជន* ........................................................ ៤១

*៥. ២. ភាពធន់សុវត្ថិភាពសាយប័រ* ........................................................ ៤២

*៥. ៣. ចំណេះដឹងហិរញ្ញវត្ថុឌីជីថល* ........................................................ ៤៣

**៦. ទិសដៅ ........................................................ ៤៨**

**ឧបសម្ព័ន្ធ ........................................................ ៥០**

*ឧបសម្ព័ន្ធ ១ - ច្បាប់ និងបទប្បញ្ញត្តិ* ........................................................ ៥០

*ឧបសម្ព័ន្ធ ២ - បញ្ជីរាយនាមសមាជិកប្រព័ន្ធទូទាត់សងប្រាក់រួម* ........................... ៥២

*ឧបសម្ព័ន្ធ ៣ - បញ្ជីរាយនាមគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់* ......................... ៥៤

*ឧបសម្ព័ន្ធ ៤ - បញ្ជីរាយនាមគ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក* .................. ៥៨

# បញ្ជីក្រាហ្វ តារាង និងប្រអប់

## ក្រាហ្វ

ក្រាហ្វ ១ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់រួម ............. ២៦

ក្រាហ្វ ២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃម៉ូឌុលបាគង ................................ ២៧

ក្រាហ្វ ៣ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់បាគង ........................ ២៨

ក្រាហ្វ ៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់បាគងតម្លៃធំ .............. ២៩

ក្រាហ្វ ៥ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃម៉ូឌុលទូទាត់សុទ្ធ .......................... ៣០

ក្រាហ្វ ៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់មូលប្បទានបត្រ ......... ៣១

ក្រាហ្វ ៧ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាបណ្ណទូទាត់ CSS ............... ៣២

ក្រាហ្វ ៨ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធធនាគារអេឡិចត្រូនិក ........ ៣៣

ក្រាហ្វ ៩ - ចំនួនភ្នាក់ងារ អតិថិជនមានគណនីរូបិយវត្ថុអេឡិចត្រូនិក និងអតិថិជន Walk-in របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ ........................................................................................ ៣៤

ក្រាហ្វ ១០ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ ............................. ៣៥

ក្រាហ្វ ១១ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័ត ...................... ៣៦

ក្រាហ្វ ១២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាធនាគារចល័ត .................. ៣៧

ក្រាហ្វ ១៣ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាធនាគារអ៊ីនធឺណិត .......... ៣៧

ក្រាហ្វ ១៤ - ចំនួនបណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងបណ្ណទូទាត់អន្តរជាតិ) .............. ៣៨

ក្រាហ្វ ១៥ - ចំនួនម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាត ................................ ៣៩

ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាមឃ្យូអរកូត ...................... ៣៩

## ប្រអប់

**ប្រអប់ ១** - កម្មវិធីទូទាត់បាគងយុវន ..... ៦

**ប្រអប់ ២** - និន្នាការនៃការផ្ទេរប្រាក់ឆ្លងដែន ..... ១៧

**ប្រអប់ ៣** - វេទិកា និងពិព័រណ៍ហិរញ្ញវត្ថុ ក្នុងឆ្នាំ២០២៥ ..... ២១

**ប្រអប់ ៤** - ការផ្តល់សេវាពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ..... ៤០

## តារាង

**តារាង ១** - លទ្ធផលនៃការវាយតម្លៃប្រព័ន្ធបាគង ..... ២៤

# អក្សរកាត់

| | | |
|---|---|---|
| BIS | Bank for International Settlements | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ |
| CSS | Cambodian Shared Switch | ខេមបូឌានស៊ែស្វីច |
| EMV | Europay, Mastercard, and VISA | ស្តង់ដារបណ្តាញបណ្ណទូទាត់អន្តរជាតិ យូរ៉ូផេ ម៉ាស្ទ័រកាត និងវីសា |
| FMI | Financial Market Infrastructures | ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ |
| MVP | Minimum Viable Product | ផលិតផលដែលអាចសម្រេចបានអប្បបរមា |
| RPC | Regional Payment Connectivity | ការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់ |
| SWIFT | Society for Worldwide Interbank Financial Telecommunication | បណ្តាញទូរគមនាគមន៍ហិរញ្ញវត្ថុនៃធនាគារទូទាំងពិភពលោក |
| UTC | Universal Trusted Credentials | គម្រោង Universal Trusted Credentials |

# បរិយាយសង្ខេប

ស្របតាមនិន្នាការពិភពលោក បរិវត្តកម្មឌីជីថលត្រូវបានចាត់ទុកជាកម្លាំងចលករចម្បងក្នុងការជំរុញសន្ទុះកំណើនសេដ្ឋកិច្ច។ ក្នុងនោះ ប្រព័ន្ធទូទាត់សងប្រាក់ដែលជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការទូទាត់សងប្រាក់ឌីជីថលប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍។ ការអភិវឌ្ឍ និងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានធនាគារជាតិនៃកម្ពុជាចាត់ទុកជាការងារអាទិភាពក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងជំរុញការទូទាត់ឌីជីថល សំដៅរួមចំណែកអភិវឌ្ឍដល់វិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៅកម្ពុជា ដោយក្នុងនោះធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់ជាបន្តបន្ទាប់។

ប្រព័ន្ធទូទាត់សងប្រាក់រួមត្រូវបានអភិវឌ្ឍ និងដាក់ឱ្យដំណើរការសាកល្បងកាលពីពាក់កណ្ដាលឆ្នាំ២០២៤ ក្នុងគោលបំណងសម្រួលដល់សមាជិក និងអតិថិជនក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថានកាន់តែងាយស្រួល ឆាប់រហ័ស និងមានសុវត្ថិភាព ព្រមទាំងបានរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងបរិយាបន្នហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០២៥ ប្រព័ន្ធទូទាត់សងប្រាក់រួមមានសមាជិកសរុបចំនួន ៧២ គ្រឹះស្ថាន ក្នុងនោះគ្រឹះស្ថានចំនួន ៥៦ បានដាក់ឱ្យដំណើរការសាកល្បង និងមានប្រតិបត្តិការចំនួន ១,៣២ ប៊ីលានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ប្រតិបត្តិការប្រមាណ ៥,៧ ដងនៃផ.ស.ស។ ប្រព័ន្ធទូទាត់សងប្រាក់រួម ត្រូវបានបែងចែកជាពីរម៉ូឌុល រួមមាន ម៉ូឌុលបាគង ក្នុងនោះមានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ និងម៉ូឌុលទូទាត់សុទ្ធ ក្នុងនោះមានសេវាទូទាត់មូលប្បទានបត្រ និងសេវាបណ្ណទូទាត់។ សេវាទូទាត់បាគង ជាសេវាទូទាត់រាយដែលកំពុងពេញនិយមក្នុងស្រទាប់យុវវ័យ ដោយសេវានេះអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការទូទាត់ប្រាក់និងផ្ទេរប្រាក់បានងាយស្រួល រហ័ស កម្រៃសេវាទាប និងសុវត្ថិភាព ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក បានកើនឡើងក្នុងអត្រា ១៥៧,៣% និង ៧៩,៧% រៀងគ្នា។ ចំណែកឯប្រតិបត្តិការរបស់សេវាទូទាត់បាគងតម្លៃធំ ក៏មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក បានកើន ១២១% និង ២៣២% រៀងគ្នា។ ទន្ទឹមនេះ សេវាទូទាត់បាគងកំពុងត្រូវបានពង្រីកមុខងារជាបន្តបន្ទាប់ ក្នុងនោះរួមមាន មុខងារសម្រួលការទូទាត់វិក្កយបត្រ មុខងារស្វែងរកព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩/ព័ត៌មានបោះឆ្នោត មុខងារតភ្ជាប់គណនីធនាគារ មុខងារទូទាត់ប្រាក់ដោយមិនត្រូវការអ៊ីនធឺណិត មុខងារច្រកទូទាត់ មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក ការដាក់ឱ្យប្រើប្រាស់សាកល្បងនូវកម្មវិធីទូទាត់បាគងទេសចរ និងកម្មវិធីទូទាត់បាគងយុវជន។ ក្នុងឆ្នាំ២០២៥ នេះ សេវាទូទាត់មូលប្បទានបត្រមាននិន្នាការថយចុះបន្តិចទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ក្នុងអត្រា ៧,៧% និង ២,១% រៀងគ្នា ស្របពេលប្រតិបត្តិការ

ទូទាត់តាមបណ្ណទូទាត់ទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ក៏មានការថយចុះគួរឱ្យកត់សម្គាល់ផងដែរ ក្នុងអត្រា ៥៣,១% និង ៥៩,៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២៤។

ធនាគារជាតិនៃកម្ពុជា បានបន្តពង្រីកវិសាលភាពកិច្ចសហប្រតិបត្តិការទ្វេភាគីលើប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមយន្តអរកូដជាមួយប្រទេសក្នុងតំបន់ ដែលកិច្ចសហប្រតិបត្តិការនេះមានគោលបំណងជំរុញវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ព្រមទាំងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ដោយបានដាក់ឱ្យដំណើរការការទូទាត់ឆ្លងដែនតាមយន្តអរកូដជាមួយប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង ជប៉ុន និងសិង្ហបុរី និងកំពុងបន្តធ្វើសន្ទានកម្មប្រព័ន្ធជាមួយប្រទេសផ្សេងទៀតផងដែរ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការការទូទាត់ឆ្លងដែនតាមយន្តអរកូដជាមួយក្រុមហ៊ុនបណ្តាញបណ្ណទូទាត់អន្តរជាតិយូញៀនផេ និងក្រុមហ៊ុនអាលីផេ ដើម្បីសម្រួលដល់ការទូទាត់ឆ្លងដែនរវាងប្រជាជនកម្ពុជា និងចិន។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើសន្ទានកម្មប្រព័ន្ធជាមួយក្រុមហ៊ុន TenPay Global ក្នុងគោលបំណងជំរុញអន្តរប្រតិបត្តិការរវាងសេវាទូទាត់បាគង និងបណ្តាញទូទាត់ចល័ត វីឆាតផេ របស់ប្រទេសចិន។

សម្រាប់កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនពហុភាគី ធនាគារជាតិនៃកម្ពុជាបានចូលរួមជាសមាជិកទី៩ ក្នុងកិច្ចសហប្រតិបត្តិការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ក្នុងតំបន់ កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ ដែលជាក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់ប្រទេសជាសមាជិកអាស៊ាន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែន និងជំរុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមជាសមាជិកអង្កេតការណ៍ក្នុងគម្រោង Nexus ដែលជាគម្រោងទូទាត់ពហុភាគី ផ្តួចផ្តើម និងអភិវឌ្ឍដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ ក្នុងគោលដៅពន្លឿនការតភ្ជាប់ការទូទាត់ឆ្លងដែន និងបង្កើនប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែនពហុភាគីតាមរយៈការប្រើប្រាស់រូបិយវត្ថុចម្រុះ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមជាសមាជិកអង្កេតការណ៍ក្នុងគម្រោង mBridge ដែលជាថ្នាលទូទាត់ឆ្លងដែនឌីជីថលពហុភាគីសម្រាប់ការទូទាត់តម្លៃធំ មានលទ្ធភាពប្រើប្រាស់រូបិយប័ណ្ណឌីជីថលចម្រុះ និងបច្ចេកវិទ្យាឌីអិលធី ដើម្បីធ្វើការទូទាត់ឆ្លងដែនបានភ្លាមៗ។ គម្រោង mBridge បានឈានដល់ដំណាក់កាលផលិតផលដែលអាចសម្រេចបានអប្បបរមាកាលពីពាក់កណ្តាលឆ្នាំ២០២៤ និងគ្រោងនឹងឈានដល់ដំណាក់កាលផលិតភាពពេញលេញ នៅពេលខាងមុខផងដែរ។

ក្រោមកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្មឆ្លងដែន កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធររូបិយវត្ថុសិង្ហបុរី បានដាក់ឱ្យដំណើរការគម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលសម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុនរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកនៃគម្រោងនៅប្រទេសទាំងពីរ ដើម្បីសម្រួលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាសហប្រធានជាមួយទីភ្នាក់ងារអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ និងមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត បានចាប់ផ្តើម

ដំណើរការសាកល្បងគម្រោង UTC នៅកម្ពុជា កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ដើម្បីផ្តល់ជាថ្នាលទិន្នន័យ និងក្របខណ្ឌទិន្នន័យជាក់លាក់មួយ ក៏ដូចជាចូលរួមដោះស្រាយបញ្ហាប្រឈមរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម។ បច្ចុប្បន្ន ថ្នាល UTC ត្រូវបានដាក់បង្ហាញសាកល្បងជាមួយគ្រឹះស្ថានជាសមាជិក និងគ្រោងដាក់ដំណើរការនៅក្នុងឆ្នាំ២០២៦។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងសិក្សាស្វែងយល់ជាមួយអាជ្ញាធររូបិយវត្ថុហុងកុងពាក់ព័ន្ធនឹងគម្រោង Ensemble ដែលជាគម្រោងអភិវឌ្ឍក្របខណ្ឌអន្តរប្រតិបត្តិការសម្រាប់ Tokenized Deposit ដែលបាននិងកំពុងប្រើប្រាស់លើប្រធានបទចំនួន ៤ រួមមាន មូលនិធិចំណូលថេរនិងការវិនិយោគ ការគ្រប់គ្រងសន្ទនីយភាពហិរញ្ញវត្ថុបៃតងនិងចីរភាព និងពាណិជ្ជកម្ម/ហិរញ្ញវត្ថុខ្សែចង្វាក់ផ្គត់ផ្គង់។

ដើម្បីឆ្លើយតបទៅនឹងនិន្នាការវិវត្តថ្មីៗនៃប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងតំបន់ និងសកល ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំធ្វើបច្ចុប្បន្នកម្មផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ២០២៦-២០៣០ បន្ទាប់ពីផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ២០២០-២០២៥ ត្រូវបានដាក់ឱ្យអនុវត្តកន្លងមកប្រកបដោយពិលាស។ សម្រាប់ផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ២០២៦-២០៣០ ធនាគារជាតិនៃកម្ពុជាបានកំណត់នូវគោលនយោបាយអាទិភាពសំខាន់ៗ ក្នុងនោះរួមមាន ក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យនិងការចែករំលែកទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុ សេវាធនាគារឌីជីថល ក្របខណ្ឌធនាគារបើកចំហ ការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី បញ្ញាសិប្បនិម្មិត អត្តសញ្ញាណឌីជីថល ក្របខណ្ឌសន្តិសុខសាយប័រ និង Quantum Computing។

ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍ និងបន្តជំរុញដាក់ឱ្យប្រើប្រាស់មុខងារបន្ថែមក្នុងសេវាទូទាត់បាគង ដើម្បីលើកកម្ពស់ការចាប់យក និងការប្រើប្រាស់នវានុវត្តន៍ឌីជីថលក្នុងវិស័យធនាគារឱ្យកាន់តែមានសក្តានុពល ដោយក្នុងនោះរួមមាន (១) មុខងារសម្រួលការទូទាត់វិក្កយបត្រ (២) មុខងារស្វែងរកព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩/ព័ត៌មានបោះឆ្នោត (៣) មុខងារតភ្ជាប់គណនីធនាគារ (៤) មុខងារទូទាត់ប្រាក់ដោយមិនត្រូវការអ៊ីនធឺណិត (៥) មុខងារច្រកទូទាត់ (៦) មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក (៧) កម្មវិធីទូទាត់បាគងទេសចរ និង (៨) កម្មវិធីទូទាត់បាគងយុវ័ន។

ក្នុងនាមជាធនាគារកណ្តាល ជាប្រតិបត្តិករ និងជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើកិច្ចដំណើរការរបស់ប្រព័ន្ធទូទាត់ ដោយក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យ និងវាយតម្លៃសេវាទូទាត់បាគងធៀបនឹងគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ហើយលទ្ធផលនៃការវាយតម្លៃទទួលបានល្អប្រសើរ។ ជំហានបន្ទាប់ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំត្រួតពិនិត្យ និងវាយតម្លៃលើថ្នាលធនាគារជាតិនៃកម្ពុជា ដែលជាថ្នាលសំខាន់ក្នុងការធ្វើប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុ។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារស្តីពី ផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ ដែលជាឯកសារស្របតាមស្តង់ដារអន្តរជាតិបង្ហាញពីយុទ្ធសាស្ត្រ ដើម្បីធានាបាននូវការបន្តប្រតិបត្តិការ

ឬការស្តារប្រព័ន្ធទូទាត់ក្នុងករណីមានការរំខាន ឬឧប្បត្តិហេតុកើតឡើង និងយុទ្ធសាស្ត្របម្រុងទុកទិន្នន័យផងដែរ។ ដោយឡែក ការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តជាប្រចាំ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយផ្តោតសំខាន់លើការអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១២ ក្នុងនោះមាន ៦ គ្រឹះស្ថាន ត្រូវបានចុះត្រួតពិនិត្យតាមផែនការប្រចាំឆ្នាំ និង ៦ គ្រឹះស្ថាន ត្រូវបានចុះត្រួតពិនិត្យ ដើម្បីសិក្សាលើការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ និងផ្លាស់ប្តូរទីតាំងថ្មី។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល ជូនមន្ត្រី-បុគ្គលិកសាខាធនាគារជាតិនៃកម្ពុជា និងសិស្ស-និស្សិតនៅតាមវិទ្យាល័យ និងសាកលវិទ្យាល័យនៃបណ្តាខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជា ក្នុងគោលដៅលើកកម្ពស់និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលមានតម្លៃសមរម្យ និងបញ្ជ្រាបចំណេះដឹងដល់សាធារណជនអំពីការបង្ការ ក៏ដូចជាទប់ស្កាត់ការឆបោកក្នុងការប្រើប្រាស់សេវាទូទាត់សងប្រាក់។ ការផ្សព្វផ្សាយនេះ ជាការងារអាទិភាពមួយដែលធនាគារជាតិនៃកម្ពុជាតែងតែយកចិត្តទុកដាក់រៀបចំជាប្រចាំ ដើម្បីផ្តល់ជាចំណេះដឹង និងព័ត៌មានសម្រាប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជននៅតាមតំបន់ជនបទ ដែលចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅមានកម្រិត។

# ស្ថិតអំពីស្ថានភាពសេវាទូទាត់សងប្រាក់

## ១. ស្ថិតិទូទៅ

| | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ (៣) |
|---|---|---|
| ចំនួនប្រជាជនសរុប (ខ្ទង់លាន) [1] | ១៧,៦៤ | ១៧,៨៥ |
| ផលិតផលក្នុងស្រុកសរុប (ខ្ទង់លានដុល្លារអាមេរិក) [2] | ៤២.៦៩៩ | ៤៩.៨៥១ |

## ២. គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ [2]

| ប្រភេទគ្រឹះស្ថាន | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | និន្នាការ |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៥៩ | ៥៩ | - |
| ធនាគារឯកទេស | ៩ | ៧ | (២២,២%) |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៤ | ៤ | - |
| គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២៩ | ៣០ | ៣,៥% |
| អ្នកដំណើរការតតិយភាគី | ៦ | ៤ | (៣៣,៣%) |

## ៣. ឧបករណ៍ទូទាត់សងប្រាក់ [2] (ឯកតាខ្ទង់លាន)

| ប្រភេទឧបករណ៍ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | និន្នាការ |
|---|---|---|---|
| **៣.១ ប្រភេទឧបករណ៍រូបវន្ត** | | | |
| បណ្ណដក/ដាក់ប្រាក់ | ២,៩១ | ២,៧២ | (៦,៥%) |
| បណ្ណឥណពន្ធ | ២,៧៦ | ២,៣៧ | (១៤,១%) |
| បណ្ណឥណទាន | ០,២៥ | ០,២៩ | ១៥,៩% |
| បណ្ណបង់ប្រាក់ជាមុន | ៦,៧០ | ១,៦៤ | (៧៥,៥%) |
| **៣.២ ប្រភេទឧបករណ៍បែបឌីជីថល** | | | |
| គណនីប្រាក់បញ្ញើអតិថិជន | ២៣,៧៤ | ៣១,៨៣ | ៣៤,១% |
| គណនីរូបិយវត្ថុអេឡិចត្រូនិក | ២០,៦៧ | ១៧,៨៩ | (១៣,៤%) |
| គណនីបាគង | ០,៦៤ | ០,៧៥ | ១៧,២% |

## ៤. បណ្តាញទូទាត់ [2] (ឯកតាខ្ទង់ពាន់)

| ចំនួនបណ្តាញទូទាត់ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | និន្នាការ |
|---|---|---|---|
| ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ | ៥,៧០ | ៥,៧៤ | ០,៧% |
| ម៉ាស៊ីនឆូតកាត | ៥៣,៦០ | ៥២,២៨ | (២,៥%) |
| ភ្នាក់ងារផ្តល់សេវាទូទាត់ | ៥៨,១០ | ៣៦,៨៦ | (៣៦,៦%) |

[1] ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ

[2] ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥. ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់រូម [២] (ឯកតាខ្ទង់លាន)

| | ឆ្នាំ២០២៤ | | ឆ្នាំ២០២៥ | | និន្នាការ | |
|---|---|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ | រៀល | ដុល្លារ |
| **៥.១ សេវាទូទាត់បាគង** | | | | | | |
| ចំនួនប្រតិ. | ២៩៩,៦៩ | ៣០៨,៥៣ | ៧៧១,១៦ | ៥៥៤,៨៩ | ១៥៧,៣១% | ៧៩,៧២% |
| ទំហំប្រាក់ | ១៧៩.៣៨៩.០៤៨ | ១០២.៣៧៤ | ២៨៥.៨៨៥.១៥៤ | ១៥២.៨១៣ | ៥៩,៣៧% | ៤៩,២៧% |
| **៥.២ សេវាទូទាត់បាគងតម្លៃធំ** | | | | | | |
| ចំនួនប្រតិ. | ០,០០០៧ | ០,០០៣ | ០,០០២ | ០,០១១ | ១២១% | ២៣២.២៥% |
| ទំហំប្រាក់ | ៣៨៣.៦០៨,៥១ | ៥៦៥,៨៤ | ៣.១៧៨.៣៩៨,៦៧ | ២.០៧៩,៨២ | ៧២៨,៥៥% | ២៦៧,៥៦% |
| **៥.៣ សេវាទូទាត់មូលប្បទានបត្រ** | | | | | | |
| ចំនួនប្រតិ. | ០,០៣៣ | ១,០១ | ០,០៣ | ០,៩៩៣ | (៧,៧២%) | (២,១០%) |
| ទំហំប្រាក់ | ២១.៦៤៩.៥៦០ | ៥៧.៥៩៣,៧៣ | ២៥.៤០៩.៦៥២,១១ | ៥២.១៦២,៦៨ | ១៧,៣៧% | (៩,៤៣%) |
| **៥.៤ សេវាបណ្ណទូទាត់តាមបណ្ណ CSS** | | | | | | |
| ចំនួនប្រតិ. | ០,១៦ | ០,០៣ | ០,០៨ | ០,០១ | (៥៣,១២%) | (៥៩,៤៧%) |
| ទំហំប្រាក់ | ៣៥.៦១៦,៩៨ | ៤,៤៨ | ១៨.៦៩០,៧៧ | ១,៨៦ | (៤៧,៥២%) | (៥៨,៥៥%) |

## ៦. ប្រតិបត្តិការនៃសេវាទូទាត់សងប្រាក់ [២] (ឯកតាខ្ទង់លាន)

| | ឆ្នាំ២០២៤ | | ឆ្នាំ២០២៥ | | និន្នាការ | |
|---|---|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ | រៀល | ដុល្លារ |
| **៦.១ សេវាទូទាត់ចល័ត (តាមគណនីរូបិយវត្ថុអេឡិចត្រូនិក)** | | | | | | |
| ចំនួនប្រតិ. | ៤៧៥,៧៨ | ៥៨៦,៩១ | ១.១៨៩,៥៧ | ៩៧៧,៥១ | ១៥០,០% | ៦៦,៦% |
| ទំហំប្រាក់ | ១៨២.២៩៤.៥៣៧ | ៥៨.៥៨១ | ២៨៦.៩០៥.១៩៣ | ៩៨.២៧១ | ៥៧,៤% | ៦៧,៨% |
| **៦.២ សេវាធនាគារចល័ត** | | | | | | |
| ចំនួនប្រតិ. | ១៩១,៣៩ | ៨៦៩,៤៤ | ៣៨០,៣២ | ១.១៩៦,៣៧ | ៩៨,៧% | ៣៧,៦% |
| ទំហំប្រាក់ | ៨៩.៨៥៧.៤៣០ | ១៧០.៧៥១ | ១៣៨.២៨៩.៧១៩ | ២២៦.៦៧៩ | ៥៣,៩% | ៣២,៨% |
| **៦.៣ សេវាធនាគារអ៊ីនធឺណិត** | | | | | | |
| ចំនួនប្រតិ. | ០,៩៧ | ៨,៦០ | ២,៥០ | ១៧,៩៣ | ១៥៧,៧% | ១០៨,៥% |
| ទំហំប្រាក់ | ១០.៩៣៨.៦៦១ | ២១.៦៩៥ | ១២.៩៦៩.២៨៥ | ៣៣.៥០៧ | ១៨,៦% | ៥៤,៤% |
| **៦.៤ សេវាបណ្ណទូទាត់តាមបណ្ណឥណពន្ធ បណ្ណឥណទាន បណ្ណដក/ដាក់ប្រាក់ និងបណ្ណទូទាត់អន្តរជាតិ [៣]** | | | | | | |
| ចំនួនប្រតិ. | - | ១៦៩,៧៧ | - | ១៦៦,៥២ | - | (១,៩%) |
| ទំហំប្រាក់ | ៤៩.៥៦២.០៣៩ | ១៤.៧៣៨ | ៤៣.៥៧៦.៨៥២ | ១៥,៣៩៥ | (១២,១%) | ៤,៥% |

[២] ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣] ប្រតិបត្តិការបណ្ណទូទាត់ រួមបញ្ចូលប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកជាមួយគ្នា

# ១. ទិដ្ឋភាពទូទៅនៃប្រព័ន្ធទូទាត់សងប្រាក់

## ១.១. ទិដ្ឋភាពទូទៅ

ប្រព័ន្ធទូទាត់សងប្រាក់ ជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុដ៏សំខាន់របស់ប្រទេស ដែលដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្តល់នូវមធ្យោបាយទូទាត់សងប្រាក់ដែលមានប្រសិទ្ធភាព និងសុវត្ថិភាព ដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ ការទូទាត់ចំពោះការទិញ-លក់ទំនិញ និងសេវា និងការជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុ។ ជាមួយនឹងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ប្រព័ន្ធទូទាត់សងប្រាក់បានក្លាយជាធាតុសំខាន់មួយក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា និងបានរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការដាក់ឱ្យប្រើប្រាស់សេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលមានតម្លៃសេវាសមរម្យ និងមានលក្ខណៈទូលំទូលាយ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម និងបានដាក់ឱ្យដំណើរការសាកល្បង ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ឱ្យកាន់តែមានភាពងាយស្រួល និងមានប្រសិទ្ធភាព និងសម្រួលដល់អតិថិជន និងសមាជិកប្រព័ន្ធក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថាន។

## ១.២. ក្របខណ្ឌបទប្បញ្ញត្តិ

ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ ឱ្យធានាបាននូវសុវត្ថិភាព ប្រសិទ្ធភាព និងនវានុវត្តន៍សម្រាប់សេវាទូទាត់សងប្រាក់។ ក្នុងបរិបទដែលប្រតិបត្តិការទូទាត់បែបឌីជីថលកំពុងមានការពេញនិយមពីសំណាក់អ្នកប្រើប្រាស់ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាប្រតិបត្តិករ និងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ មានតួនាទីរៀបចំបទប្បញ្ញត្តិសំខាន់ៗ ដើម្បីលើកកម្ពស់នវានុវត្តន៍ ក៏ដូចជាធានាឱ្យបាននូវស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ និងការពារផលប្រយោជន៍អ្នកប្រើប្រាស់។

ធនាគារជាតិនៃកម្ពុជា បានដាក់ចេញសេចក្តីជូនដំណឹងស្តីពី "កាតព្វកិច្ចក្នុងការបញ្ជូនរបាយការណ៍ពីកម្រៃលើសេវាផ្ទេរប្រាក់អន្តរជាតិសម្រាប់អតិថិជន" ក្នុងគោលបំណងការពារផលប្រយោជន៍អតិថិជន ធានាការយកកម្រៃសេវាផ្ទេរប្រាក់របស់គ្រឹះស្ថានមានតម្លៃសមរម្យ និងតម្លាភាព បន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថា គ្រឹះស្ថានដែលកំពុងផ្តល់សេវាផ្ទេរប្រាក់អន្តរជាតិតាមរយៈប្រព័ន្ធ SWIFT អ្នកដំណើរការតតិយភាគី និងកិច្ចសហការជាមួយដៃគូផ្ទេរប្រាក់នៅក្រៅប្រទេស បានកំណត់ និងកែប្រែកម្រៃសេវាផ្ទេរប្រាក់ជាប្រចាំ ដែលការណ៍នេះបង្កជាផលលំបាកដល់អតិថិជនក្នុងការប្រើប្រាស់

សេវាផ្ទេរប្រាក់អន្តរជាតិ។ លើសពីនេះ ក្នុងគោលបំណងលើកកម្ពស់ប្រតិបត្តិការទូទាត់សងប្រាក់នៅកម្ពុជា និងប្រតិបត្តិការទូទាត់ឆ្លងដែនប្រកបដោយសុវត្ថិភាពនិងបរិយាបន្ន ការដាក់ចេញយន្តការការពារអតិថិជន និងប្រព័ន្ធទូទាត់ឱ្យដំណើរការប្រកបដោយសុវត្ថិភាព ជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់សំដៅការពារផលប្រយោជន៍របស់អ្នកធ្វើប្រតិបត្តិការទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែន។ ដោយមើលឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញសេចក្តីណែនាំស្តីពី "ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការទូទាត់សងប្រាក់នៅកម្ពុជា និងប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែន" ដើម្បីបង្ការការក្លែងបន្លំ និងទប់ស្កាត់ការទូទាត់ប្រាក់ និងផ្ទេរប្រាក់ឆ្លងដែនដែលមានភាពមិនប្រក្រតី ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនជាមួយប្រទេសជាដៃគូឱ្យកាន់តែមានប្រសិទ្ធភាព។ ដើម្បីបន្តជំរុញការប្រើប្រាស់ប្រាក់រៀល និងផ្តល់ភាពងាយស្រួលដល់អាជីវករ ឬពាណិជ្ជករដែលទទួលការទូទាត់ពីភ្ញៀវជាតិនិងអន្តរជាតិ និងពង្រីកកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនឱ្យកាន់តែទូលំទូលាយ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញសេចក្តីណែនាំស្តីពី "ការលើកកម្ពស់ការទូទាត់តាមខេអេចឃ្យូអរកូតសម្រាប់ពាណិជ្ជករ" ក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀលសម្រាប់ការទូទាត់សងប្រាក់តាមខេអេចឃ្យូអរកូតឱ្យកាន់តែពិលាស និងមានប្រសិទ្ធភាព។ បច្ចុប្បន្ន និន្នាការនៃការធ្វើប្រតិបត្តិការទូទាត់សងប្រាក់ជាឌីជីថលបន្តកើនឡើងគួរឱ្យកត់សម្គាល់ ដែលបង្ហាញពីការចូលរួមរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការជំរុញបរិវត្តកម្មឌីជីថលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការកើនឡើងនូវប្រតិបត្តិការក្លែងបន្លំ ឬវិវាទប្រតិបត្តិការពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ នៅបន្តកើតមានឡើងដែលបណ្តាលឱ្យមានភាពរអាក់រអួលដល់ដំណើរការនៃការផ្តល់សេវាទូទាត់សងប្រាក់នាំឱ្យបាត់បង់ទំនុកចិត្តពីសាធារណជន ដោយសារមិនមានការជូនដំណឹងបានត្រឹមត្រូវ និងទាន់ពេលវេលាពីអតិថិជននិងគ្រឹះស្ថានសាមី។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវសេចក្តីណែនាំស្តីពី "ការពង្រឹងនីតិវិធីនៃការជូនដំណឹងអំពីភាពរអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ជូនដល់សាធារណជន" ក្នុងគោលបំណងទប់ស្កាត់ហានិភ័យ ជាពិសេសដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រតិបត្តិការទូទាត់សងប្រាក់ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងទំនុកចិត្តពីសាធារណជនមកលើប្រព័ន្ធធនាគារ។

ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងរៀបចំសេចក្តីព្រាង (១) ប្រកាសស្តីពី ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រង និងកំណត់ពីនីតិវិធីសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការស្នើសុំការអនុញ្ញាតប្រើប្រាស់ភ្នាក់ងារផ្តល់សេវាធនាគារដែលមានកម្រិត និង (២) ប្រកាសស្តីពី ប្រតិបត្តិការទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីគ្រប់គ្រងប្រតិបត្តិការ និងប្រតិបត្តិករទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិក។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងរៀបចំសេចក្តីព្រាង (១) សេចក្តីណែនាំស្តីពី ការគ្រប់គ្រងគណនីអាណត្តិព្យាបាល (២) សេចក្តីណែនាំស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និង (៣) សេចក្តីណែនាំស្តីពី ការកំណត់សោហ៊ុយសេវារដ្ឋបាលសម្រាប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ សម្រាប់ប្រព័ន្ធ

ទូទាត់សងប្រាក់រួម ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម ក្នុងគោលបំណងគាំទ្រដល់កិច្ចដំណើរការប្រព័ន្ធ និងទុកជាឯកសារចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិក។ សេចក្តីព្រាងប្រកាសនេះ គ្រោងនឹងដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០២៦ ផងដែរ។

## ១.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់

ស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅក្នុងយុគសម័យឌីជីថលនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់សម្រាប់គាំទ្រដល់ប្រតិបត្តិការទូទាត់សងប្រាក់ជាបន្តបន្ទាប់។ ដើម្បីបន្តជំរុញការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ធនាគារជាតិនៃកម្ពុជាបានរៀបចំអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដោយបានធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលមានស្រាប់មកស្ថិតក្រោមប្រព័ន្ធទូទាត់រួមតែមួយ ដើម្បីសម្រួលដល់អតិថិជន និងគ្រឹះស្ថានសមាជិកក្នុងការធ្វើប្រតិបត្តិការទូទាត់អន្តរគ្រឹះស្ថាន ដោយប្រព័ន្ធទូទាត់សងប្រាក់រួមនឹងបែងចែកប្រតិបត្តិការដោយស្វ័យប្រវត្តិផ្អែកលើទំហំប្រាក់ និងពេលវេលាទូទាត់។ ក្រោមការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ឧបករណ៍ទូទាត់សងប្រាក់ដែលមានលក្ខណៈស្រដៀងគ្នាត្រូវបានដាក់រួមបញ្ចូលគ្នាទៅតាមប្រភេទម៉ូឌុល ក្នុងនោះម៉ូឌុលបាគង មានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ និងម៉ូឌុលទូទាត់សុទ្ធ មានសេវាទូទាត់មូលប្បទានបត្រ និងសេវាបណ្ណទូទាត់។ ប្រព័ន្ធទូទាត់សងប្រាក់រួមត្រូវបានដាក់ឱ្យដំណើរការសាកល្បងកាលពីពាក់កណ្ដាលឆ្នាំ២០២៤ ហើយបច្ចុប្បន្នមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកសរុបចំនួន ៧២ គ្រឹះស្ថាន ក្នុងនោះគ្រឹះស្ថានចំនួន ៥៦ បានដាក់ឱ្យដំណើរការសាកល្បង និង ១៦ គ្រឹះស្ថានផ្សេងទៀតកំពុងធ្វើសន្ទានកម្មប្រព័ន្ធ។

សេវាទូទាត់បាគង បានក្លាយជាសេវាទូទាត់សងប្រាក់ដ៏មានប្រជាប្រិយភាពនៅកម្ពុជា ដែលបានសម្រួលដល់ប្រតិបត្តិការទូទាត់សងប្រាក់មានដូចជា ការទូទាត់តាមរយៈខេអេចឃ្យូអរកូត ការផ្ទេរប្រាក់អន្តរគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តជំរុញ និងអភិវឌ្ឍមុខងារថ្មីៗក្នុងសេវាទូទាត់បាគងប្រកបដោយនវានុវត្តន៍ ក្នុងនោះរួមមាន មុខងារសម្រួលការទូទាត់វិក្កយបត្រ មុខងារតភ្ជាប់គណនីធនាគារ មុខងារស្វែងរកព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩/ព័ត៌មានបោះឆ្នោត មុខងារច្រកទូទាត់ មុខងារទូទាត់ប្រាក់ដោយមិនត្រូវការអ៊ីនធឺណិត មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក កម្មវិធីទូទាត់បាគងទេសចរ និងកម្មវិធីទូទាត់បាគងយុវន ក្នុងគោលបំណងពង្រីកលទ្ធភាពក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងផ្តល់ឱកាសដល់សិស្សានុសិស្សអាចរៀនសូត្រអំពីចំណេះដឹងហិរញ្ញវត្ថុ និងឌីជីថលតាំងពីវ័យក្មេង។ ដើម្បីចូលរួមលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលប្រកបដោយបរិយាបន្ន និងផ្តល់ភាពងាយស្រួលដល់អាជីវករដែលទទួលការទូទាត់ពីភ្ញៀវទេសចរ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញសេចក្តីណែនាំស្តីពី

"ការលើកកម្ពស់ការទូទាត់តាមខេអេចឃ្យូអរកូតសម្រាប់ពាណិជ្ជករ" ដោយតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអនុវត្តខេអេចឃ្យូអរកូតរួមសម្រាប់ពាណិជ្ជករ និងផ្តល់អាទិភាពធ្វើប្រតិបត្តិការទូទាត់សងប្រាក់ជាប្រាក់រៀល ព្រមទាំងអភិវឌ្ឍមុខងារលើកម្មវិធីទូទាត់ចល័ត/ធនាគារចល័ត ដោយកំណត់យកប្រាក់រៀលជាគណនីគោល។ សេចក្តីណែនាំនេះ ក៏ជំរុញអតិថិជនដែលប្រកបអាជីវកម្ម មុខរបរ និងការងារដែលជាសកម្មភាពស្របច្បាប់ឱ្យចុះបញ្ជីតាមបណ្តាញសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ព្រមទាំងបង្កើតគណនីនិងខេអេចឃ្យូអរកូតពាណិជ្ជករ ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពី ការដាក់ឱ្យប្រើប្រាស់ទម្រង់ស្តង់ដារខេអេចឃ្យូអរតែមួយ ក្នុងគោលដៅជំរុញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុលើការអភិវឌ្ឍទម្រង់ឃ្យូអរសម្រាប់ដាក់តាំងនៅគ្រប់ទីតាំងពាណិជ្ជករ ជៀសវាងការប្រើប្រាស់ឃ្យូអរកូតច្រើន និងលើកកម្ពស់ការទូទាត់ជាប្រាក់រៀលតាមជម្រើសរបស់អតិថិជន។

ក្នុងគោលបំណងរក្សាសុវត្ថិភាព ស្ថិរភាព និងប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចដែលមានប្រតិបត្តិការតម្លៃធំ ជាពិសេសប្រតិបត្តិការទីផ្សារហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យប្រើប្រាស់សាកល្បងសេវាទូទាត់បាគងតម្លៃធំ កាលពីពាក់កណ្តាលឆ្នាំ២០២៤ ដើម្បីសម្រួលប្រតិបត្តិការទូទាត់ដែលមានតម្លៃធំ និងលើកកម្ពស់ការទូទាត់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសផ្តល់នូវភាពងាយស្រួលសម្រាប់បុគ្គលនិងធុរជនអាចធ្វើប្រតិបត្តិការទីផ្សារហិរញ្ញវត្ថុជាឌីជីថលដែលមានទំហំប្រាក់ធំ។ សេវាទូទាត់បាគងតម្លៃធំប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេនដើម្បីធានាការទូទាត់ភ្លាមៗ កាត់បន្ថយហានិភ័យក្នុងការទូទាត់ និងប្រើប្រាស់សម្រាប់ទូទាត់លទ្ធផលចុងក្រោយរបស់ឧបករណ៍ទូទាត់សងប្រាក់ដទៃទៀត។

សេវាទូទាត់មូលប្បទានបត្រ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ដំណើរការនៃការផាត់ទាត់ និងទូទាត់អន្តរធនាគារទាក់ទងនឹងមូលប្បទានបត្រដោយធានាថាមូលនិធិត្រូវបានផ្ទេរប្រកបដោយភាពត្រឹមត្រូវ។ តាមរយៈសេវានេះ អតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់អាចធ្វើប្រតិបត្តិការទូទាត់តាមរយៈមូលប្បទានបត្រប្រកបដោយភាពងាយស្រួល និងកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់។ ក្នុងឆ្នាំ២០២៥ ការប្រើប្រាស់មូលប្បទានបត្រទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក មានការថយចុះបន្តិច ធៀបនឹងឆ្នាំមុន។

បណ្ណទូទាត់ ជាឧបករណ៍ហិរញ្ញវត្ថុដ៏សំខាន់មួយសម្រាប់សម្រួលដល់ការទូទាត់ និងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់។ បណ្ណទូទាត់មិនត្រឹមតែចូលរួមកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការធ្វើប្រតិបត្តិការទូទាត់សងប្រាក់ផងដែរ។ ជាមួយនឹងការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់សេវាបណ្ណទូទាត់ CSS ក្នុងគោលបំណងលើកកម្ពស់ការទូទាត់ឌីជីថល ការទូទាត់តាមពាណិជ្ជកម្មអេឡិចត្រូនិក និងការរីកចម្រើនក្នុងវិស័យធនាគារនៅកម្ពុជា។ សេវាបណ្ណទូទាត់ CSS ជា

មធ្យោបាយសម្រាប់អតិថិជនក្នុងការធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានតាមរយៈបណ្ណទូទាត់ឥណពន្ធ CSS លើគ្រប់ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាតរបស់គ្រឹះស្ថានសមាជិក CSS។ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញគោលនយោបាយសម្រាប់គ្រឹះស្ថានសមាជិកអនុវត្តស្តង់ដារ EMV Chip ជំនួសបច្ចេកវិទ្យា Magnetic Stripe ក្នុងគោលបំណងលើកកម្ពស់សុវត្ថិភាពបណ្ណទូទាត់ CSS ក៏ដូចជាទប់ស្កាត់ការក្លែងបន្លំ និងហានិភ័យផ្សេងៗនៃការប្រើប្រាស់បណ្ណទូទាត់ ព្រមទាំងលើកកម្ពស់កិច្ចដំណើរការនៃប្រតិបត្តិការដកប្រាក់ និងការអនុលោមតាមស្តង់ដារនៃសេវាបណ្ណទូទាត់ CSS និងកំណត់ទំហំប្រាក់ដូចគ្នាក្នុងមួយប្រតិបត្តិការ និងកម្រៃសេវាថេរនៅលើម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិរួមទាំងបណ្ណទូទាត់ CSS។

## ១.៤. សេវាទូទាត់សងប្រាក់

សេវាទូទាត់សងប្រាក់ឌីជីថលដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានដាក់ឱ្យប្រើប្រាស់យ៉ាងទូលំទូលាយ និងប្រកបដោយនវានុវត្តន៍ស្របពេលដែលហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ និងបច្ចេកវិទ្យាថ្មីៗកំពុងបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការអភិវឌ្ឍក្នុងវិស័យហិរញ្ញវត្ថុឱ្យកាន់តែប្រសើរ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ប្រតិបត្តិការទូទាត់សងប្រាក់ឌីជីថលនៅប្រទេសកម្ពុជាមានសន្ទុះកើនឡើងយ៉ាងខ្លាំងតាមរយៈការដាក់ឱ្យប្រើប្រាស់សេវាធនាគារជាអេឡិចត្រូនិក និងឧបករណ៍ទូទាត់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសការទូទាត់តាមខេអេចឃ្យូអរកូតជាប្រាក់រៀលដែលកំពុងពេញនិយមសម្រាប់អ្នកប្រើប្រាស់ជាប្រជាជនកម្ពុជា និងជនបរទេសដែលធ្វើដំណើរមកប្រទេសកម្ពុជា។ វឌ្ឍនភាពទាំងនេះបានមកពីកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដាក់ឱ្យដំណើរការគំរូបរិច្ឆិនភាពខេអេចឃ្យូអរកូតនៅឆ្នាំ២០២២ ដែលផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថាន តាមរយៈខេអេចឃ្យូអរកូតបានដោយពិលាស។ លើសពីនេះ ប្រជាជនកម្ពុជាក៏អាចធ្វើប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមឃ្យូអរកូតបានយ៉ាងងាយស្រួល និងសុវត្ថិភាព តាមរយៈកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់ និងក្រុមហ៊ុនបណ្តាញទូទាត់អន្តរជាតិផងដែរ។

## ប្រអប់ ១ - កម្មវិធីទូទាត់បាគងយុវជន

កម្មវិធីទូទាត់បាគងយុវជន ត្រូវបានដាក់ឱ្យដំណើរការក្នុងដំណាក់កាលសាកល្បង កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ ដែលកម្មវិធីនេះផ្តល់លទ្ធភាពដល់ក្មេងវ័យជំទង់ដែលជាអនីតិជនមានអាយុក្រោម ១៥ឆ្នាំ ពុំទាន់មានអត្តសញ្ញាណប័ណ្ណ អាចប្រើប្រាស់សេវាធនាគារឌីជីថលដ៏ទំនើប តាមរយៈកម្មវិធីទូទាត់បាគងយុវជន ដោយគ្រាន់តែប្រើប្រាស់ប័ណ្ណសម្គាល់ខ្លួនសិស្ស ក្នុងការចុះឈ្មោះជាការស្រេច។ បន្ថែមពីនេះ កម្មវិធីទូទាត់បាគងយុវជន នឹងជួយបណ្តុះទម្លាប់ដល់យុវជនឱ្យចេះគ្រប់គ្រងហិរញ្ញវត្ថុ និងការចាយវាយត្រឹមត្រូវតាំងពីវ័យក្មេង។ ធនាគារជាតិនៃកម្ពុជា ក៏បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការចូលរួមផ្សព្វផ្សាយ និងលើកទឹកចិត្តសិស្សានុសិស្សប្រើប្រាស់កម្មវិធីនេះឱ្យបានច្រើនកុះករផងដែរ។






# ២. ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

ស្ថិតក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ធនាគារជាតិនៃកម្ពុជា ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់និងផ្ទេរប្រាក់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំរុញការអភិវឌ្ឍនៅក្នុងវិស័យទេសចរណ៍ លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងបានរួមចំណែកគាំទ្រដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងក្របខណ្ឌអាស៊ាន និងអន្តរជាតិ តាមរយៈការផ្តល់ជាមធ្យោបាយសម្រួលដល់ការផ្ទេរប្រាក់និងទូទាត់ថ្លៃទំនិញនិងសេវា ដែលមានកម្រៃប្រតិបត្តិការទាបសម្រាប់ពលករទេសន្តរប្រវេសន៍ និងធុរកិច្ចជន។ ក្នុងគោលបំណងពង្រឹង និងពង្រីកកិច្ចសហការក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍនិងបន្តពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់និងផ្ទេរប្រាក់ឆ្លងដែនរួមមាន (១) កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនទ្វេភាគី (២) កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនពហុភាគី (៣) ការផ្ទេរប្រាក់ឆ្លងដែន (៤) កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្មឆ្លងដែន និង (៥) កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនជាមួយក្រុមហ៊ុនបណ្តាញបណ្ណទូទាត់អន្តរជាតិ។

## ២.១. កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនទ្វេភាគី

ក្នុងឆ្នាំ២០២៥ កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍនិងតភ្ជាប់ការទូទាត់សងប្រាក់ឆ្លងដែនទ្វេភាគីដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ សមិទ្ធផលគួរជាទីមោទននោះ ឆ្លុះបញ្ចាំងតាមរយៈការដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់សងប្រាក់ឆ្លងដែនជាមួយបណ្តាប្រទេសជាដៃគូ និងគ្រឹះស្ថានអន្តរជាតិជាច្រើន ដែលការណ៍នេះបានរួមចំណែកក្នុងការពង្រីកវិសាលភាពនៃការទូទាត់សងប្រាក់ឆ្លងដែនកាន់តែទូលំទូលាយ រហ័ស និងប្រកបដោយប្រសិទ្ធភាព និងជំរុញការទូទាត់ជាឌីជីថលរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ កាត់បន្ថយហានិភ័យនៃការកាន់ក្រដាស់ប្រាក់និងចំណាយក្នុងការប្តូររូបិយប័ណ្ណនៅពេលធ្វើប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែន។ តាមរយៈកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនទ្វេភាគីដែលបានដាក់ឱ្យដំណើរការជាផ្លូវការកន្លងមក ភ្ញៀវទេសចរអន្តរជាតិដែលមកកម្សាន្តនៅក្នុងប្រទេសកម្ពុជា អាចប្រើប្រាស់កម្មវិធីធនាគារចល័តដែលមានស្រាប់ ដើម្បីទូទាត់ថ្លៃទំនិញនិងសេវាជារូបិយវត្ថុរបស់ខ្លួនដោយស្កេនខេអេចឃ្យូអរកូតនៅតាមបញ្ជរពាណិជ្ជករនៅទូទាំងប្រទេសកម្ពុជា ចំណែកឯប្រជាជនកម្ពុជាដែលធ្វើដំណើរកម្សាន្តទៅក្រៅប្រទេស ក៏អាចប្រើប្រាស់កម្មវិធីទូទាត់បាគង ឬកម្មវិធីធនាគារចល័តរបស់ខ្លួនស្កេនទូទាត់ជា

រូបិយវត្ថុរៀលនៅតាមបញ្ជររបស់ពាណិជ្ជករដែលជាបណ្ដាញប្រតិបត្តិការនៅតាមបណ្ដាប្រទេសជាដៃគូបានយ៉ាងងាយស្រួល។

គិតត្រឹមដំណាច់ឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលនៃប្រទេសជាដៃគូបានអភិវឌ្ឍ និងដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនទាំងពីរដំណាក់កាល ដោយផ្ដល់លទ្ធភាពក្នុងការស្កេនទូទាត់គ្នាទៅវិញទៅមក ជាមួយបណ្ដាប្រទេសក្នុងក្របខណ្ឌអាស៊ាន រួមមានប្រទេសថៃ ឡាវ វៀតណាម និងម៉ាឡេស៊ី។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនដំណាក់កាលទី១ ជាមួយប្រទេសសិង្ហបុរី ជប៉ុន និងកូរ៉េខាងត្បូង ហើយនឹងបន្តធ្វើសន្ធានកម្មប្រព័ន្ធសម្រាប់ដំណាក់កាលទី២ នៅឆ្នាំបន្តបន្ទាប់។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាកំពុងបន្តអភិវឌ្ឍគម្រោងទូទាត់ឆ្លងដែនជាមួយបណ្ដាប្រទេសផ្សេងទៀតដូចជា ប្រទេសឥណ្ឌា និងហ្វីលីពីនផងដែរ។

## ការចុះអនុស្សរណៈយោគយល់ និងការដាក់ឱ្យដំណើរការការទូទាត់ឆ្លងដែនទ្វេភាគីជាមួយបណ្ដាប្រទេសនានា ក្នុងឆ្នាំ២០២៥







*ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដដំណាក់កាលទី២ រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនបណ្ដាញបណ្ណទូទាត់អន្តរជាតិយូញៀនផេ (បាគងស្កេនយូញៀនផេ) នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*





*ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដដំណាក់កាលទី២ រវាងប្រទេសកម្ពុជា និងម៉ាឡេស៊ី (កម្ពុជាស្កេនម៉ាឡេស៊ី) នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី*





ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដដំណាក់កាលទី១ រវាងប្រទេសកម្ពុជា និងជប៉ុន (បាគងស្កេន JPQR) នាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៥ នៅទីក្រុងអូសាកា ប្រទេសជប៉ុន







ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដដំណាក់កាលទី១ រវាងប្រទេសកម្ពុជា និងសិង្ហបុរី (បាគងស្កេន SGQR) នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅប្រទេសសិង្ហបុរី







ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដ រវាងប្រទេសកម្ពុជា និងឡាវ (ដំណាក់កាលទី២៖ ឡាវស្កេនខេអេចយូអរកូដ) នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ

## ២.២. កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនពហុភាគី

### ២.២.១. កិច្ចសហប្រតិបត្តិការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់

ក្របខណ្ឌកិច្ចសហប្រតិបត្តិការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការទូទាត់សងប្រាក់ឆ្លងដែនឱ្យកាន់តែមានភាពរហ័ស តម្លៃសមរម្យ មានតម្លាភាព និងប្រកបដោយបរិយាបន្ន។ ទន្ទឹមនេះ ក្របខណ្ឌកិច្ចសហប្រតិបត្តិការនេះក៏មានគោលដៅគាំទ្រដល់សកម្មភាពសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន ព្រមទាំងបង្កើនលទ្ធភាពពង្រីកទីផ្សារបានកាន់តែទូលំទូលាយសម្រាប់សហគ្រាសធុនតូចនិងមធ្យម សម្រួលដល់ការធ្វើពាណិជ្ជកម្មនិងការផ្ទេរប្រាក់កាន់តែប្រសើរឡើង។ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាចូលរួមក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់ជាមួយសមាជិកអាស៊ានដ៏ទៃទៀត ដែលជាជំហានថ្មីមួយទៀតក្នុងការពង្រីកវិសាលភាពនៃការតភ្ជាប់ប្រព័ន្ធហិរញ្ញវត្ថុក្នុងតំបន់ឱ្យកាន់តែទូលំទូលាយ និងរឹងមាំ។

### ២.២.២. សមាជិកអង្កេតការណ៍ក្នុងគម្រោង Nexus

គម្រោង Nexus ត្រូវបានអភិវឌ្ឍឡើងក្រោមគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលនវានុវត្តន៍នៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ ក្នុងគោលបំណងតភ្ជាប់ប្រព័ន្ធទូទាត់ពហុភាគី ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងផ្តល់នូវសេវាទូទាត់ឆ្លងដែនដែលមានតម្លៃសមរម្យ រហ័ស និងសុវត្ថិភាពសម្រាប់ប្រជាជនក្នុងតំបន់អាស៊ាន។ គម្រោងនេះត្រូវបានអនុម័តជាផ្លូវការនៅក្នុងកិច្ចប្រជុំទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី១៨ កាលពីខែមេសា ឆ្នាំ២០២២ និងត្រូវបានកំណត់ជាការងារអាទិភាពដោយក្រុមការងារគណៈកម្មការប្រព័ន្ធទូទាត់អាស៊ាន ក្នុងឆ្នាំ២០២៣។ បច្ចុប្បន្ន គម្រោងនេះមានគ្រឹះស្ថានជាសមាជិកសរុបចំនួន ៦ ក្នុងនោះរួមមាន ធនាគារកណ្តាលនៃប្រទេសម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ ឥណ្ឌូនេស៊ី និងឥណ្ឌា ជាសមាជិកស្ថាបនិកនៃគម្រោង និងមានធនាគារជាតិនៃកម្ពុជាចូលរួមជាសមាជិកអង្កេតការណ៍ពិសេសចាប់តាំងពីឆ្នាំ២០២៣។

### ២.២.៣. សមាជិកអង្កេតការណ៍ក្នុងគម្រោង mBridge

គម្រោង mBridge ត្រូវបានអភិវឌ្ឍឡើងជាថ្នាលទូទាត់ឆ្លងដែនដុលជាឌីជីថលដែលមានលទ្ធភាពប្រើប្រាស់រូបិយប័ណ្ណឌីជីថលចម្រុះ ក្នុងការធ្វើប្រតិបត្តិការទូទាត់ឆ្លងដែន ព្រមទាំងមានលទ្ធភាពសម្រួលដល់ការប្តូររូបិយប័ណ្ណរវាងប្រទេសជាសមាជិកផងដែរ។ គម្រោង mBridge ត្រូវបានផ្តួចផ្តើមអភិវឌ្ឍដោយមានការសហការគ្នារវាងមជ្ឈមណ្ឌលនវានុវត្តន៍នៃធនាគារសម្រាប់ការទូទាត់អន្តរជាតិជាមួយអាជ្ញាធររូបិយវត្ថុហុងកុង ធនាគារកណ្តាលថៃ ធនាគារកណ្តាលចិន និងធនាគារកណ្តាលនៃប្រទេសអារ៉ាប់រួម ព្រមទាំងមានសមាជិកអង្កេតការណ៍ពីធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុជាច្រើន ក្នុងនោះធនាគារជាតិនៃកម្ពុជាក៏បានចូលរួមជាសមាជិកអង្កេតការណ៍តាំងពីដើមឆ្នាំ២០២៤។ គម្រោង mBridge កំពុងស្ថិតក្នុងដំណាក់កាលបញ្ចប់ MVP ហើយនឹងឈានដល់ដំណាក់កាលដំណើរការ

ពេញលេញនៅក្នុងឆ្នាំ២០២៦ ខាងមុខនេះ។ ធនាគារជាតិនៃកម្ពុជាបានតាមដានយ៉ាងយកចិត្តទុកដាក់លើវឌ្ឍនភាពនៃការអភិវឌ្ឍគម្រោង និងបានចូលរួមក្នុងកិច្ចប្រជុំជាប្រចាំ ដែលកិច្ចប្រជុំចុងក្រោយបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីក្រុងស៊ិនជិន ប្រទេសចិន។

## ២.៣. វឌ្ឍនភាពនៃការផ្ទេរប្រាក់ឆ្លងដែន

ការផ្ទេរប្រាក់របស់ពលករទេសន្តប្រវេសន៍ បានក្លាយជាប្រភពទុនបរទេសដ៏មានស្ថិរភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងកម្ពុជា។ សារៈសំខាន់នេះត្រូវបានទទួលស្គាល់ដោយស្ថាប័នអន្តរជាតិជាច្រើន រួមទាំងធនាគារពិភពលោក និងបានកំណត់និយមន័យថា ការផ្ទេរប្រាក់គឺរួមបញ្ចូលទាំងការផ្ទេរប្រាក់ផ្ទាល់ខ្លួន ប្រាក់ឈ្នួល ឬប្រាក់ចំណូលរបស់ពលករទេសន្តប្រវេសន៍ ដែលរួមបញ្ចូលទាំងពលករទេសន្តប្រវេសន៍រយៈពេលខ្លី និងរយៈពេលវែង ព្រមទាំងកម្មករតាមព្រំដែន។ និយមន័យនេះបង្ហាញពីលក្ខណៈបត់បែននៃលំហូរក្នុងការផ្ទេរប្រាក់ និងសារៈសំខាន់នៃការផ្ទេរប្រាក់លើការសន្សំប្រាក់ ការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសការពង្រឹងភាពធន់នៃសេដ្ឋកិច្ច។

ក្នុងបរិបទកម្ពុជា ផ្អែកលើទិន្នន័យពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅឆ្នាំ២០២៥ ប្រទេសកម្ពុជាមានពលករអន្តោប្រវេសន៍ប្រមាណ ០,៤៣ លាននាក់ ស្មើនឹង ២,៤៧% នៃចំនួនប្រជាជនសរុប ដែលធ្វើការក្នុងវិស័យផ្សេងៗគ្នាដូចជាវិស័យកសិកម្ម នេសាទ សំណង់ ផលិតកម្ម និងសេវាកម្មនៅតាមបណ្តាប្រទេសដូចជា កូរ៉េខាងត្បូង ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី ហុងកុង ថៃ និងអារ៉ាប៊ីសាអូឌីត។ កន្លងមក ប្រាក់ចំណូលរបស់ពលករទេសន្តប្រវេសន៍ដែលរកបាន ត្រូវផ្ញើត្រឡប់មកកាន់ប្រទេសកម្ពុជាវិញតាមបណ្តាញប្រតិបត្តិការផ្លូវការជាច្រើនរួមមាន តាមរយៈគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បណ្តាញប្រតិបត្តិការ SWIFT ប្រតិបត្តិករផ្ទេរប្រាក់ និងកិច្ចសហប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ។ ជាក់ស្តែង ក្នុងឆ្នាំ២០២៥ ទំហំប្រាក់ផ្ទេរមកប្រទេសកម្ពុជាមានប្រមាណ ២,០៥ ប៊ីលានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៤,១% នៃផ.ស.ស។



អនុលោមតាមប្រកាសលេខ ធ១៤.០១៧.១៦១ ប្រ.ក ស្តីពី ការគ្រប់គ្រងលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក្នុងគោលបំណងជំរុញនវានុវត្តន៍ និងលើកកម្ពស់ការប្រកួតប្រជែងក្នុងការផ្តល់សេវាទូទាត់សងប្រាក់ ព្រមទាំងពង្រីកលទ្ធភាពក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ឬការផ្ទេរប្រាក់អន្តរជាតិចេញ-ចូលប្រទេសកម្ពុជា បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាផ្ទេរប្រាក់ ឬការផ្ទេរប្រាក់អន្តរជាតិដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាសរុបចំនួន ២៣ គ្រឹះស្ថាន ក្នុងនោះរួមមាន ធនាគារពាណិជ្ជចំនួន ១៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ១ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ៦ សហការជាមួយគ្រឹះស្ថានក្រៅប្រទេសជាដៃគូចំនួន ១១៦ ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ៣០ ផ្តល់សេវាផ្ទេរប្រាក់ចូលប្រទេសកម្ពុជា គ្រឹះស្ថានចំនួន ១២ ផ្តល់សេវាផ្ទេរប្រាក់ចេញពីប្រទេសកម្ពុជា និងគ្រឹះស្ថានចំនួន ៧៤ ផ្សេងទៀតផ្តល់សេវាផ្ទេរប្រាក់ទាំងផ្ទេរប្រាក់ចូល និងផ្ទេរប្រាក់ចេញពីប្រទេសកម្ពុជា។ អតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនចេញ-ចូលប្រទេសកម្ពុជា តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាដូចបានរៀបរាប់ខាងលើ តាមប្រព័ន្ធ SWIFT ភ្នាក់ងាររបស់អ្នកដំណើរការតតិយភាគី រួមមាន MoneyGram, Western Union និង RIA។ ដោយឡែក អតិថិជនក៏អាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ចេញក្រៅប្រទេសតាមរយៈក្រុមហ៊ុនបណ្តាញបណ្ណទូទាត់អន្តរជាតិដូចជា ម៉ាស្ទ័រកាត វីសា និងយូញៀនផេ ព្រមទាំងវីសា B2B។ ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនចេញ-ចូលប្រទេសកម្ពុជាដែលធ្វើឡើងតាមរយៈកិច្ចសហប្រតិបត្តិការក្នុងវិស័យធនាគារសរុបមានចំនួន ៤,៤៨ លានប្រតិបត្តិការ (ក្នុងនោះប្រតិបត្តិការផ្ទេរចូលមានចំនួន ៣,១៥ លានប្រតិបត្តិការ និងប្រតិបត្តិការផ្ទេរចេញមានចំនួន ១,៣៣ លានប្រតិបត្តិការ) សមមូលនឹងទំហំប្រាក់សរុបចំនួន ៨៥,៣៩ ប៊ីលានដុល្លារអាមេរិក (ក្នុងនោះមាន ៤០,៦៦ ប៊ីលានដុល្លារអាមេរិកជាប្រតិបត្តិការផ្ទេរចូល និង ៤៤,៧៣ ប៊ីលានដុល្លារអាមេរិកជាប្រតិបត្តិការផ្ទេរចេញ)។






ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតលើកិច្ចសហប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ឬការផ្ទេរប្រាក់អន្តរជាតិឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២៣ នៅក្នុងប្រទេសកម្ពុជា ដែលអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ចេញ-ចូលក្នុងប្រទេសកម្ពុជា ជាមួយគ្រឹះស្ថានជាដៃគូនៅក្រៅប្រទេសចំនួន ១១៦ គ្រឹះស្ថាន។

**២៣ គ្រឹះស្ថាន**

ធនាគារពាណិជ្ជ ១៦
គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៦
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១

**១១៦ គ្រឹះស្ថាន**

១២ គ្រឹះស្ថាន ផ្តល់សេវាផ្ទេរប្រាក់ចេញក្រៅប្រទេស
៣០ គ្រឹះស្ថាន ផ្តល់សេវាផ្ទេរប្រាក់ចូលកម្ពុជា
៧៤ គ្រឹះស្ថាន ផ្តល់សេវាទាំងផ្ទេរប្រាក់ចេញ និងចូល

## ២.៤. កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្មឆ្លងដែន

ដើម្បីគាំទ្រដល់ការធ្វើពាណិជ្ជកម្មឆ្លងដែន លើកកម្ពស់ផលិតភាពនិងការនាំចេញ និងជំរុញការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម ធនាគារជាតិនៃកម្ពុជាបានសហការ និងចូលរួមអភិវឌ្ឍគម្រោងហិរញ្ញប្បទានពាណិជ្ជកម្មឆ្លងដែន រួមមាន គម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ និងគម្រោង UTC។

### ២.៤.១. គម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ

គម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ ត្រូវបានអភិវឌ្ឍឡើងក្រោមគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្ររវាងធនាគារជាតិនៃកម្ពុជា និងអាជ្ញាធររូបិយវត្ថុសិង្ហបុរី និងត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤។ គម្រោងនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល ដើម្បីបង្កើតឱ្យមានកិច្ចព្រមព្រៀងជាមុនរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃប្រទេសទាំងពីរ។ តាមរយៈយន្តការនេះ សហគ្រាសធុនមីក្រូ តូច និងមធ្យមនៃប្រទេសទាំងពីរនឹងទទួលបាននូវភាពងាយស្រួលក្នុងការទទួលបានសេវាហិរញ្ញវត្ថុឆ្លងដែនដែលជំរុញដល់ការធ្វើពាណិជ្ជកម្មឱ្យកាន់តែរីកចម្រើន និងប្រកបដោយភាពប្រកួតប្រជែង ដែលការណ៍នេះនឹងជំរុញការនាំចេញ និងគាំទ្រដល់ការអភិវឌ្ឍ និងភាពរីកចម្រើននៃសេដ្ឋកិច្ចឌីជីថលរវាងកម្ពុជា និងសិង្ហបុរី។

បច្ចុប្បន្ន គម្រោងនេះមានការចូលរួមយ៉ាងសកម្មពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសរុបចំនួន ១០ ដែលកំពុងដំណើរការតភ្ជាប់ប្រព័ន្ធជាមួយក្រុមហ៊ុន Proxtera ដែលជាអ្នកសម្របសម្រួលផ្នែកបច្ចេកទេស។ ក្នុងនោះ ភាគីកម្ពុជាមានគ្រឹះស្ថានចំនួន ៧ ដែលបានចូលរួមក្នុងគម្រោង រួមមាន ធនាគារអេស៊ីលីដា, ស្ថាបនា, ហ្វីលីព, វីង, វឌ្ឍនៈអាស៊ីចំកាត់, អេសប៊ីអាយ លីហួរ និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។ ចំណែកឯភាគីសិង្ហបុរីមានគ្រឹះស្ថានចំនួន ៣ រួមមាន ANEXT Bank, Liquid Group និង Sing Investments & Finance។ គ្រឹះស្ថានជាសមាជិកនៃគម្រោងនេះអាចផ្លាស់ប្តូរព័ត៌មានរបស់អតិថិជនរវាងគ្នា ប៉ុន្តែដោយផ្អែកលើការយល់ព្រមពីអតិថិជន ដើម្បីផ្តល់ធាតុចូលក្នុងការវាយតម្លៃឥណទាន និងកាត់បន្ថយហានិភ័យដល់គ្រឹះស្ថានជាសមាជិកនៅពេលផ្តល់ហិរញ្ញប្បទានឆ្លងដែន។ គម្រោងនេះមិនត្រឹមតែជួយសម្រួលដល់លំហូរពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាគំរូ

នៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុដែលជ្រើសយកបច្ចេកវិទ្យាជាគោល ដើម្បីគាំទ្រដល់អាជីវកម្មខ្នាតតូចនិងមធ្យមឱ្យមានលទ្ធភាពប្រកួតប្រជែងទីផ្សារក្នុងតំបន់។




### ២.៤.២. គម្រោងសាកល្បង UTC

គម្រោងសាកល្បង UTC ត្រូវបានបង្កើតឡើងក្នុងគោលបំណងកសាងក្របខណ្ឌទិន្នន័យឌីជីថលដែលអាចទុកចិត្តបាន ដើម្បីជួយសម្រួលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការអនុវត្តនីតិវិធី ពិនិត្យ និងវាយតម្លៃការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម។ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប គម្រោងនេះមានគោលដៅកាត់បន្ថយហានិភ័យនៃកិច្ចសន្យាធានា និងកាត់បន្ថយតម្រូវការវត្ថុធានានៅពេលស្នើសុំហិរញ្ញប្បទាន ដែលជាកត្តាគន្លឹះក្នុងការផ្តល់លទ្ធភាពឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យម ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការបានកាន់តែងាយស្រួល និងជំរុញផលិតភាពនាំចេញឱ្យកាន់តែប្រសើរ។ ក្នុងការអភិវឌ្ឍគម្រោងនេះ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីជាសហប្រធានជាមួយទីភ្នាក់ងារអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ ដោយមានការចូលរួមពីក្រុមការងារសាកល្បង ដែលរួមមានសមាជិកស្នូលមកពីអន្តរក្រសួង និងស្ថាប័នរដ្ឋសំខាន់ៗដូចជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សាជីវកម្មធានាឥណទានកម្ពុជា និងការិយាល័យឥណទានកម្ពុជា។

លើសពីនេះ គម្រោងសាកល្បង UTC ក៏ទទួលបានការគាំទ្រពីវិស័យឯកជន តាមរយៈក្រុមប្រឹក្សាយោបល់ស្ថាប័នឯកជន ដែលរួមមានគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដូចជា ធនាគារអេស៊ីលីដា ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ធនាគារកាណាឌីយ៉ា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ធនាគារស្ថាបនា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ និងក្រុមហ៊ុន Banhji។ បច្ចុប្បន្ន ផ្ទាលបច្ចេកវិទ្យា UTC កំពុងត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុន DFINITY Foundation ហើយបានឈានដល់ដំណាក់កាលដាក់បង្ហាញសាកល្បងជាមួយគ្រឹះស្ថានជាសមាជិក និងបន្តអភិវឌ្ឍគម្រោងសាកល្បងនេះបន្តទៀត។

តាមការគ្រោងទុក ថ្នាលឌីជីថលដ៏មានសារៈសំខាន់នេះនឹងត្រូវដាក់ឱ្យដំណើរការជាផ្លូវការនៅដើមឆ្នាំ២០២៦ ដើម្បីជាសសរស្តម្ភថ្មីមួយគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។




## ២.៥. កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនជាមួយក្រុមហ៊ុនបណ្ដាញបណ្ណទូទាត់អន្តរជាតិ

ក្នុងគោលដៅពង្រីកវិសាលភាពប្រព័ន្ធទូទាត់ជាតិឱ្យកាន់តែទូលំទូលាយទៅកាន់សកលលោក និងគាំទ្រដល់វិស័យទេសចរណ៍ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនបណ្ដាញបណ្ណទូទាត់អន្តរជាតិធំៗ។ កិច្ចសហប្រតិបត្តិការនេះ ផ្ដោតសំខាន់លើការជំរុញអន្តរប្រតិបត្តិការឆ្លងដែន ដែលផ្ដល់លទ្ធភាពឱ្យភ្ញៀវទេសចរអន្តរជាតិអាចប្រើប្រាស់មធ្យោបាយទូទាត់ដែលមានស្រាប់របស់ពួកគេ ដើម្បីធ្វើប្រតិបត្តិការនៅពេលធ្វើដំណើរមកកម្ពុជា តាមរយៈប្រព័ន្ធបាគង និងការស្កេនខេអេចឃ្យូ-អរកូត។




ជាក់ស្ដែង កាលពីខែសីហា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ និងបានតភ្ជាប់ជាមួយក្រុមហ៊ុនបណ្ដាញបណ្ណទូទាត់អន្តរជាតិ ម៉ាស្ទ័រកាត និងវីសា។ យន្តការនេះផ្ដល់លទ្ធភាពឱ្យភ្ញៀវទេសចរអន្តរជាតិអាចភ្ជាប់បណ្ណទូទាត់របស់ពួកគេមកកាន់កម្មវិធីទូទាត់បាគងទេសចរ ដើម្បីធ្វើប្រតិបត្តិការស្កេនខេអេចឃ្យូអរកូតដូចជាអ្នកប្រើប្រាស់ក្នុងស្រុក ដែលជួយកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់សុទ្ធ បង្កើនភាពងាយស្រួល និងតម្លាភាពក្នុងប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់ភ្ញៀវទេសចរ។ ទន្ទឹមនឹងការតភ្ជាប់ជាមួយបណ្ដាញទូទាត់អន្តរជាតិ ធនាគារជាតិនៃកម្ពុជា សម្រេចបានសមិទ្ធផលសំខាន់ៗជាមួយក្រុមហ៊ុនបណ្ដាញបណ្ណទូទាត់អន្តរជាតិយូញៀនផេ

តាំងពីចុងឆ្នាំ២០២៣ ដោយផ្តល់លទ្ធភាពឱ្យអតិថិជនអាចធ្វើការស្កេនទូទាត់ថ្លៃទំនិញ និងសេវានៅកម្ពុជាបានយ៉ាងងាយស្រួល។ ជាពិសេស កិច្ចសហប្រតិបត្តិការជាមួយយូញៀនផេនេះ បានឈានដល់ដំណាក់កាលទី២ នៅដើមឆ្នាំ២០២៥ ដែលផ្តល់លទ្ធភាពឱ្យប្រជាជនកម្ពុជាអាចធ្វើការទូទាត់ឆ្លងដែនដោយស្កេនយូអរកូតរបស់យូញៀនផេនៅក្នុងប្រទេសចិន និងបណ្តាប្រទេសសមាជិកដទៃទៀតដែលសហការជាមួយបណ្តាញយូញៀនផេ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយក្រុមហ៊ុនទូទាត់អន្តរជាតិ អាលីផេ កាលពីចុងឆ្នាំ២០២៤ ដើម្បីសម្រួលដល់ការទូទាត់របស់អតិថិជននៃបណ្តាប្រទេសដែលជាដៃគូទាំងអស់ អាចទូទាត់ថ្លៃទំនិញនិងសេវាតាមរយៈការស្កេនខេអេចយូអរកូតរបស់ពាណិជ្ជករនៅក្នុងប្រទេសកម្ពុជាដែលមានគណនីជាប្រាក់រៀលផងដែរ។













ដើម្បីពង្រីកសក្តានុពលនៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិនឱ្យកាន់តែទូលំទូលាយ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុន TenPay Global កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥។ អនុស្សរណៈយោគយល់នេះមានគោលបំណងបង្កើតក្របខណ្ឌអន្តរប្រតិបត្តិការរវាងប្រព័ន្ធបាគង និងបណ្តាញទូទាត់ចល័តវីឆាតផេ ដើម្បីសម្របសម្រួលដល់ការទូទាត់ឆ្លងដែនរវាងប្រទេសទាំងពីរឱ្យកាន់តែមានភាពជិតស្និត ព្រមទាំងឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុទំនើប និងតម្រូវការរបស់អ្នកប្រើប្រាស់ក្នុងយុគសម័យឌីជីថល។



## ប្រអប់ ២ - និន្នាការនៃការផ្ទេរប្រាក់ឆ្លងដែន

ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនចេញ-ចូលប្រទេសកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសប្រជាជននៅតាមជនបទដែលពឹងផ្អែកមួយផ្នែក ឬទាំងស្រុងលើចំណូលដែលទទួលបានពីក្រៅប្រទេស ដើម្បីផ្គត់ផ្គង់ការរស់នៅប្រចាំថ្ងៃ។ ដោយពិនិត្យឃើញពីសារៈសំខាន់នៃប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកក្នុងការជំរុញកិច្ចសហប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ឬការផ្ទេរប្រាក់អន្តរជាតិ ដើម្បីពង្រីកលទ្ធភាពក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ចេញ-ចូលប្រទេសកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ជាមួយនឹងកម្រៃសេវាទាប និងមានភាពងាយស្រួល។ ជាក់ស្តែង ផ្អែកលើទិន្នន័យនៃប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនគិតចាប់ពីឆ្នាំ២០២០ រហូតដល់ឆ្នាំ២០២៥ បង្ហាញថា ទាំងចំនួន និងទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសចំពោះប្រតិបត្តិការផ្ទេរចូលក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០២៥ ចំនួនប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនសរុបមានចំនួន ៤,៤៨ លានប្រតិបត្តិការ កើនឡើងប្រមាណ ៨% ខណៈទំហំប្រាក់សរុបមានប្រមាណ ៨៥,៣៩ ប៊ីលានដុល្លារអាមេរិក កើនឡើង ១៥% ធៀបនឹងឆ្នាំ២០២៤។

**ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ឆ្នាំ២០២០ - ២០២៥**



# ៣. បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍

## ៣.១. និន្នាការទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បច្ចេកវិទ្យាឌីជីថលបានដើរតួនាទីកាន់តែសំខាន់ក្នុងការផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាព និងជួយសម្រួលដល់ការរក្សាបានប្រក្រតីភាពនៃសកម្មភាព និងប្រតិបត្តិការរបស់វិស័យសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់។ ក្នុងចំណោមនោះ ការចាប់យក និងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុទាំងក្នុងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានសន្ទុះ និងកំពុងតែបោះជំហានក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ដែលបានជួយសម្រួលដល់ការរស់នៅប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់ ការប្រកបអាជីវកម្មក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមទាំងមូល។ សន្ទុះនៃការអភិវឌ្ឍទាំងនេះ បាននិងកំពុងក្លាយជាកាលានុវត្តភាពថ្មី ដើម្បីជំរុញការអភិវឌ្ឍ នវានុវត្តន៍ឌីជីថល ព្រមទាំងបង្កើតធុរកិច្ចថ្មីបច្ចេកវិទ្យាហិរញ្ញវត្ថុដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបាននូវការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដ៏រស់រវើកដែលស្របទៅនឹងមុំទី៥ នៃបញ្ចកោណទី៥ ស្តីពី ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញក្នុងនីតិកាលទី៧ នេះ។ ដោយមើលឃើញពីសក្តានុពលរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់ក្នុងការរៀបចំក្របខណ្ឌគតិយុត្តដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២០-២០២៥ ត្រូវបានរៀបចំឡើង ផ្តោតលើសសរស្តម្ភសំខាន់ៗចំនួន ៣ ដែលជាឧត្តមានុវត្តន៍អន្តរជាតិ ឆ្លើយតបទៅនឹងវិធានការគោលនយោបាយនិងអាទិភាពយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ដែលមានចក្ខុវិស័យរយៈពេលវែងអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក។ គោលនយោបាយនេះ មានគោលបំណងអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ ភាពជឿទុកចិត្ត និងគុណភាពជីវិតរបស់អ្នកប្រើប្រាស់ក្នុងយុគសម័យឌីជីថល តាមរយៈការកំណត់នូវគោលដៅចម្បង រួមមាន ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និងការជំរុញការអភិវឌ្ឍ និងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ។

បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍ឌីជីថល បានក្លាយជាចលករមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់របស់ប្រទេសកម្ពុជាឱ្យកាន់តែទំនើប មានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយបរិយាបន្ន។ ការរីកចម្រើនថ្មីនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនេះ បានផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដាក់ចេញនូវផលិតផលនិងសេវាទូទាត់បែបឌីជីថលប្រកបដោយនវានុវត្តន៍ដល់សាធារណជន មានដូចជា ការទូទាត់តាមទូរស័ព្ទចល័ត ការទូទាត់ខេអេចឃ្យូអរកូត ការផ្តល់ប្រាក់កម្ចីតាមអនឡាញ ការដាក់ប្រាក់សន្សំបែបឌីជីថល និងការដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិដែលមានមុខងារសម្បូរបែប (ដក/ដាក់ប្រាក់ ទូទាត់វិក្កយបត្រ បោះពុម្ពបណ្ណទូទាត់ ដោយពុំប្រើបណ្ណទូទាត់ជាដើម)។ ដោយឡែក ចំពោះសេវាបម្រើអតិថិជន គ្រឹះស្ថានបានអភិវឌ្ឍមុខងារ Chatbot សម្រាប់ជួយដោះស្រាយបញ្ហាដល់អតិថិជន ២៤ម៉ោង ក្នុងមួយថ្ងៃ និង ៧ថ្ងៃ ក្នុងមួយសប្តាហ៍ ព្រមទាំងសេវាបម្រើអតិថិជនផ្សេងៗទៀតដូចជា ការចុះឈ្មោះបើកគណនីធនាគារ/គណនីរូបិយវត្ថុអេឡិចត្រូនិក អតិថិជនក៏អាចចុះឈ្មោះអនឡាញបានយ៉ាងងាយស្រួលតាមកម្មវិធីធនាគារចល័ត ឬកម្មវិធីទូទាត់ចល័ត ដោយបានធ្វើការកំណត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក។ ទាំងនេះជានវានុវត្តន៍ថ្មីៗដែលបានដាក់ចេញស្របតាមនិន្នាការរីកចម្រើននៅក្នុងវិស័យធនាគារ ដែលការណ៍នេះបានសបញ្ជាក់អំពីដំណើរការឆ្ពោះទៅរកសេដ្ឋកិច្ចបែបឌីជីថល ដែលជាគោលដៅរបស់រាជរដ្ឋាភិបាល។

## ៣.២. នវានុវត្តន៍ឌីជីថល

នវានុវត្តន៍ឌីជីថល បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងប្រតិបត្តិការឌីជីថលនៅក្នុងប្រទេសកម្ពុជា។ ដើម្បីលើកកម្ពស់ការចាប់យក និងការប្រើប្រាស់នវានុវត្តន៍ឌីជីថលក្នុងវិស័យធនាគារឱ្យកាន់តែមានសក្តានុពល ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់បាគងឱ្យមានមុខងារកាន់តែងាយស្រួលប្រកបដោយនវានុវត្តន៍។ មុខងារថ្មីៗក្នុងប្រព័ន្ធបាគងដែលបានអភិវឌ្ឍបន្ថែមមានដូចខាងក្រោម៖

- **មុខងារបាគងសម្រួលការទូទាត់វិក្កយបត្រ៖** ធនាគារជាតិនៃកម្ពុជាកំពុងសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីអភិវឌ្ឍមុខងារទូទាត់តាមខេអេចឃ្យូអរកូតនៅលើវិក្កយបត្រដោយផ្ទាល់ដូចជា វិក្កយបត្រសម្រាប់បង់ថ្លៃទឹក ភ្លើង និងប្រព័ន្ធបង់ប្រាក់ចំណតរថយន្តនៅអាកាសយានដ្ឋានអន្តរជាតិតេជោជាដើម ដែលនឹងសម្រួលដល់ការទូទាត់វិក្កយបត្របែបឌីជីថលជូនដល់សាធារណជន និងស្ថាប័នក្នុងវិស័យសាធារណៈ។
- **មុខងារបាគងសម្រាប់ស្វែងរកព័ត៌មានចាក់វ៉ាក់សាំង និងព័ត៌មានបោះឆ្នោត៖** ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងសុខាភិបាល ក្នុងការស្វែងរកព័ត៌មាននៃការចាក់វ៉ាក់សាំងកូវីដ-១៩ និងកំពុងសិក្សាលទ្ធភាពបន្ថែមក្នុងកិច្ចសហការជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំដៅផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់កម្មវិធីបាគងអាចពិនិត្យ និងស្វែងរកឈ្មោះនិងទិន្នន័យបោះឆ្នោតបានយ៉ាងងាយស្រួល និងឆាប់រហ័ស។

- **មុខងារបាគងតភ្ជាប់គណនីធនាគារ៖** ជាមធ្យោបាយដែលអតិថិជនអាចភ្ជាប់គណនីបាគងរបស់ខ្លួនជាមួយគណនីរបស់គ្រឹះស្ថានធនាគារដោយផ្ទាល់។ គិតត្រឹមឆ្នាំ២០២៥ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសមាជិកចំនួន ៣២ បានធ្វើសន្ធានកម្មរួចរាល់។

- **មុខងារបាគងទូទាត់ប្រាក់ដោយមិនត្រូវការអ៊ីនធឺណិត៖** ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍមុខងារទូទាត់សងប្រាក់ដោយពុំត្រូវការអ៊ីនធឺណិត ដើម្បីសម្រួលដល់ការទូទាត់ និងទទួលប្រាក់ប្រចាំថ្ងៃរបស់សាធារណជន និងពាណិជ្ជករទូទាំងប្រទេសកម្ពុជា។

- **មុខងារបាគងសម្រាប់ច្រកទូទាត់៖** ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធដោយផ្តល់លទ្ធភាពជាច្រកទូទាត់ និងប្រមូលចំណូលជូនដល់ក្រសួង-ស្ថាប័នក្នុងវិស័យសាធារណៈ ដោយបានសហការអភិវឌ្ឍប្រព័ន្ធជាមួយក្រសួងមហាផ្ទៃ ដើម្បីសម្រួលដល់ការទូទាត់កម្រៃសេវាច្រកចេញ-ចូលតែមួយ សហការជាមួយក្រសួងពាណិជ្ជកម្មក្នុងការអភិវឌ្ឍផ្លេតហ្វម Cambodia Trade ឱ្យមានលទ្ធភាពទទួលការទូទាត់រវាងអតិថិជននិងអាជីវករដែលចុះឈ្មោះប្រើប្រាស់និងធ្វើពាណិជ្ជកម្មនៅក្នុងផ្លេតហ្វម និងសហការជាមួយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដើម្បីសម្រួលដល់ការទូទាត់របស់សាធារណជនដែលប្រើប្រាស់សេវារបស់ក្រសួង។

- **មុខងារបាគងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក៖** ធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើម និងកំពុងធ្វើនវានុវត្តន៍បន្ថែមទៅលើប្រព័ន្ធបាគង ដោយប្រើប្រាស់មុខងារផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង ដែលមុខងារបន្ថែមនេះនឹងផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានដែលជាសមាជិកបាគងទាំងអស់អាចប្រើប្រាស់ទិន្នន័យសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនរបស់ខ្លួនតាមរយៈមុខងារបាគងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិកបានយ៉ាងឆាប់រហ័ស សុវត្ថិភាព និងប្រកបដោយទំនុកចិត្ត។

- **បាគងទេសចរ៖** ធនាគារជាតិនៃកម្ពុជាបានរួមចំណែកលើកស្ទួយវិស័យទេសចរណ៍នៅកម្ពុជាដោយបានដាក់ឱ្យដំណើរការជាបឋមកម្មវិធីទូទាត់បាគងទេសចរ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយភ្ញៀវទេសចរដែលមកកម្ពុជា អាចទាញយកកម្មវិធីបាគងទេសចរ និងភ្ជាប់ជាមួយបណ្ណទូទាត់អន្តរជាតិដូចជា ម៉ាស្ទ័រកាត និងវីសា ដើម្បីទូទាត់ទំនិញ និងសេវាផ្សេងៗជាមួយខេអេចឃ្យូអរកូតរបស់ពាណិជ្ជករទូទាំងប្រទេសកម្ពុជាប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាពខ្ពស់។

- **បាគងយុវនៃ៖** ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍ និងដាក់ឱ្យដំណើរការសាកល្បងកម្មវិធីទូទាត់បាគងយុវនៃ ព្រមទាំងបានស្នើសុំកិច្ចសហការពីក្រសួងអប់រំ យុវជន និងកីឡាក្នុងការផ្សព្វផ្សាយ និងជំរុញឱ្យសិស្សានុសិស្សប្រើប្រាស់កម្មវិធីបាគងយុវនៃនេះឱ្យកាន់តែច្រើន ហើយសិស្សានុសិស្សដែលមានអាយុក្រោម ១៥ឆ្នាំ អាចប្រើប្រាស់ប័ណ្ណសម្គាល់ខ្លួនសិស្សក្នុងការចុះឈ្មោះប្រើប្រាស់កម្មវិធីបាគងយុវនៃ ដើម្បីអាចទទួលបានបទពិសោធន៍ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលរួមមាន ការសន្សំប្រាក់ ការផ្ទេរប្រាក់រវាងគណនីបាគងយុវនៃនិងគណនីបាគង និងការទូទាត់ប្រាក់តាមរយៈការស្កេនខេអេចឃ្យូអរកូត។

## ប្រអប់ ៣ - វេទិកា និងពិព័រណ៍ហិរញ្ញវត្ថុ ក្នុងឆ្នាំ២០២៥

នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជាបានចូលរួមវេទិកាជំនាញសម្រាប់អនាគត ស្ដីពី ស្ត្រីទូទាំងសកលលោកក្នុងសម័យបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត នៅប្រទេសសិង្ហបុរី។ ក្នុងវេទិកានេះ លោកជំទាវ បណ្ឌិត បានមានប្រសាសន៍ថា បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត មានតួនាទីសំខាន់ក្នុងការអភិវឌ្ឍ និងស្វែងរកដំណោះស្រាយប្រកបដោយនវានុវត្តន៍ ដែលមានតម្រូវការកាន់តែទូលំទូលាយ និងចាំបាច់ត្រូវមានការចូលរួមពីអ្នកដឹកនាំជាស្ត្រីនៅទូទាំងសកលលោក ដើម្បីលើកកម្ពស់លទ្ធភាពទទួលបាន និងប្រើប្រាស់ទិន្នន័យដែលជាធនធានផ្ដល់ដោយបច្ចេកវិទ្យានេះ។ ទន្ទឹមនេះ ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ទាមទារឱ្យការទទួលខុសត្រូវ តម្លាភាព និងតុល្យភាពនៃទិន្នន័យ។ លើសពីនេះ នៅពេលដែលស្ត្រីមានគោលបំណងក្នុងការប្រើប្រាស់ទិន្នន័យទាំងនោះច្បាស់លាស់ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតអាចជួយស្ត្រីក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ផងដែរ ស្របពេលដែលបច្ចេកវិទ្យាឌីជីថលកំពុងរីកចម្រើននៅទូទាំងពិភពលោក។

នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជាបានចូលរួមផ្សព្វផ្សាយអំពីនិន្នាការវិវត្តថ្មីៗនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី។ គួររំលេចថា ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ជាវេទិកាសកលដែលមានការចូលរួមពីអ្នករៀបចំគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកដឹកនាំក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីចែករំលែកចំណេះដឹង និងសហការរួមគ្នាក្នុងការបង្កើតប្រព័ន្ធហិរញ្ញវត្ថុឌីជីថលដែលមានសុវត្ថិភាព និងបរិយាបន្ន។ ក្នុងវេទិកានេះ លោកជំទាវ បណ្ឌិត បានចែករំលែកអំពីការកំណត់នូវទស្សនៈក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន។






# ៤. ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជា ជាអាជ្ញាធរគ្រប់គ្រង អភិវឌ្ឍ និងត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា។ តួនាទីនេះត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា (១៩៩៦)។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធ្វើឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល និងដើម្បីធានាថាប្រព័ន្ធទាំងនោះគោរពតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈ-កម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ។ ក្រៅពីការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាក៏មានតួនាទីក្នុងការត្រួតពិនិត្យនិងតាមដានជាប្រចាំលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីធានាពីសុក្រិតភាពពីការអនុវត្តស្របតាមប្រកាសស្តីពី "ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់" និងក្នុងគោលបំណងរក្សាសុវត្ថិភាព សុខុមាលភាព និងផ្តល់ទំនុកចិត្តដល់សាធារណជន។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា បានអនុវត្តលើការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយអនុលោមទៅតាមវិធីសាស្ត្រត្រួតពិនិត្យលើហានិភ័យ និងការត្រួតពិនិត្យលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ សំដៅកាត់បន្ថយហានិភ័យ និងធានាសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

## ៤.១. ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

ក្នុងនាមជាអាជ្ញាធរគ្រប់គ្រង អភិវឌ្ឍ និងត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់និងទីផ្សារហិរញ្ញវត្ថុ ដែលមានតួនាទីសម្រាប់ទូទាត់ ផាត់ទាត់ ឬកត់ត្រាប្រតិបត្តិការទូទាត់មូលបត្រ និស្សន្ទវត្ថុ ឬប្រតិបត្តិការហិរញ្ញវត្ថុផ្សេងទៀត។ គណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ បានសម្រេចកំណត់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុជា ៥ ផ្នែកសំខាន់ៗដូចជា៖

- **ប្រព័ន្ធទូទាត់សងប្រាក់៖** យោងតាមនិយមន័យដែលកំណត់ដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ ប្រព័ន្ធទូទាត់សងប្រាក់ជាសំណុំនៃឧបករណ៍ទូទាត់ នីតិវិធីធនាគារ និងជាទូទៅរួមមានប្រព័ន្ធផ្ទេរមូលនិធិអន្តរធនាគារដែលធានាដល់ចរាចរូបិយវត្ថុ។ ជាធម្មតាប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានគេស្គាល់ថាជាមធ្យោបាយមួយសម្រាប់ឱ្យអ្នកចូលរួមក្នុងប្រព័ន្ធធ្វើការផ្ទេរប្រាក់។
- **មជ្ឈមណ្ឌលរក្សាទុកមូលបត្រកណ្តាល៖** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធដែលរក្សាទុក និងកត់ត្រាម្ចាស់កម្មសិទ្ធមូលបត្រជាទម្រង់អេឡិចត្រូនិក។

- **ប្រព័ន្ធទូទាត់មូលបត្រ៖** សំដៅដល់ប្រព័ន្ធដែលធ្វើការទូទាត់ និងអនុញ្ញាតឱ្យមានការផ្ទេរកម្មសិទ្ធរបស់មូលបត្រនៅពេលដែលមានការទូទាត់ជោគជ័យ។
- **សមភាគីកណ្តាល៖** សំដៅដល់ក្រុមហ៊ុនដែលធ្វើជាម្ចាស់ដៃគូផ្ទាល់ចំពោះរាល់កិច្ចសន្យាជួញដូរលើឧបករណ៍និស្សន្ទមួយ ឬច្រើន ពោលគឺក្លាយជាភាគីអ្នកទិញចំពោះរាល់អ្នកលក់ និងក្លាយជាភាគីអ្នកលក់ចំពោះរាល់អ្នកទិញ។
- **និហិតដ្ឋានប្រតិបត្តិការជួញដូរ៖** សំដៅដល់មជ្ឈមណ្ឌលប្រមូល កត់ត្រា និងរក្សាទុកទិន្នន័យប្រតិបត្តិការជួញដូរកណ្តាលជាអេឡិចត្រូនិក។

ស្របទៅនឹងតួនាទីនិងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវភាពធន់ និងស្ថិរភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជាប្រកបដោយនវានុវត្តន៍ និងបរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងត្រួតពិនិត្យ វាយតម្លៃ និងតាមដានគ្រប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលអភិវឌ្ឍ និងគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធទូទាត់សងប្រាក់នានា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជានាពេលអនាគត។

### ៤.១.១. ការវាយតម្លៃប្រព័ន្ធទូទាត់ធៀបជាមួយគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ

ដើម្បីបង្កើតនូវវិធីសាស្ត្រជាក់លាក់ក្នុងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានរៀបចំ និងដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ កាលពីឆ្នាំ២០២០ ដែលជាឯកសារមូលដ្ឋានកំណត់អំពីវិសាលភាព និងយន្តការសម្រាប់យកមកធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីកម្រិតហានិភ័យចម្បងៗរបស់ប្រព័ន្ធទូទាត់សងប្រាក់។ បច្ចុប្បន្ន ប្រព័ន្ធទូទាត់សងប្រាក់ចម្បងដែលស្ថិតក្រោមវិសាលភាពនៃការត្រួតពិនិត្យមានដូចជា ប្រព័ន្ធទូទាត់សងប្រាក់រួម ប្រព័ន្ធធនាគារអេឡិចត្រូនិក និងផ្ទាលធនាគារជាតិនៃកម្ពុជា។ ចំពោះប្រព័ន្ធទូទាត់សងប្រាក់ផ្សេងៗទៀតដែលអភិវឌ្ឍនាពេលអនាគត ក៏នឹងត្រូវស្ថិតនៅក្រោមវិសាលភាពនៃការត្រួតពិនិត្យផងដែរ ប្រសិនបើប្រព័ន្ធនោះអាចនឹងបង្កហានិភ័យដល់ការដួលរលំជាប្រព័ន្ធ និងជាប្រព័ន្ធទូទាត់សងប្រាក់ដែលមានលក្ខណៈសំខាន់ជាប្រព័ន្ធ។

បន្ទាប់ពីបានដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់រួចមក កាលពីឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធបាគងធៀបជាមួយនឹងគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។ ជាលទ្ធផលនៃការត្រួតពិនិត្យបានបង្ហាញថា ប្រព័ន្ធបាគងអនុលោមទៅតាមបទដ្ឋានស្តង់ដារគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុបានយ៉ាងត្រឹមត្រូវ ដូចមានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង១ ៖ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធបាគង**

| គោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ | គោរព បានល្អ | គោរពបាន ភាគច្រើន | គោរព បានខ្លះ | មិនគោរព បាន |
|---|---|---|---|---|
| គោលការណ៍ទី១ មូលដ្ឋានគតិយុត្ត | ✓ | | | |
| គោលការណ៍ទី២ អភិបាលកិច្ច | ✓ | | | |
| គោលការណ៍ទី៣ ក្របខណ្ឌសម្រាប់គ្រប់គ្រងហានិភ័យ | | ✓ | | |
| គោលការណ៍ទី៤ ហានិភ័យឥណទាន | ✓ | | | |
| គោលការណ៍ទី៥ ប្រតិភោគ | ✓ | | | |
| គោលការណ៍ទី៦ ម៉ាជីន | | | | |
| គោលការណ៍ទី៧ ហានិភ័យសន្ទនីយភាព | ✓ | | | |
| គោលការណ៍ទី៨ ការទូទាត់បញ្ចប់ | ✓ | | | |
| គោលការណ៍ទី៩ សាច់ប្រាក់ទូទាត់ | ✓ | | | |
| គោលការណ៍ទី១០ ការប្រគល់ឧបករណ៍ជារូបវន្ត | | | | |
| គោលការណ៍ទី១១ មជ្ឈមណ្ឌលរក្សាមូលបត្រ | | | | |
| គោលការណ៍ទី១២ ប្រព័ន្ធសម្រាប់ទូទាត់ដោះដូរតម្លៃ | | | | |
| គោលការណ៍ទី១៣ វិធាននិងនីតិវិធីអំពីការទូទាត់បរាជ័យរបស់អ្នកចូលរួម | ✓ | | | |
| គោលការណ៍ទី១៤ វិយោគកម្មនិងការបែងចែក | | | | |
| គោលការណ៍ទី១៥ ហានិភ័យធុរកិច្ច | ✓ | | | |
| គោលការណ៍ទី១៦ ហានិភ័យការថែរក្សា និងការវិនិយោគ | | | | |
| គោលការណ៍ទី១៧ ហានិភ័យប្រតិបត្តិការ | | ✓ | | |
| គោលការណ៍ទី១៨ ការចូលជាសមាជិកប្រើប្រព័ន្ធ | ✓ | | | |
| គោលការណ៍ទី១៩ ការចាត់ថ្នាក់សមាជិកចូលរួម | ✓ | | | |
| គោលការណ៍ទី២០ ការតភ្ជាប់រវាង FMI | | | | |
| គោលការណ៍ទី២១ ប្រសិទ្ធភាពនិងប្រសិទ្ធផល | ✓ | | | |
| គោលការណ៍ទី២២ វិធានទំនាក់ទំនង និងបទដ្ឋានស្តង់ដារ | ✓ | | | |
| គោលការណ៍ទី២៣ ការបង្ហាញវិធាននិងនីតិវិធី និងទិន្នន័យ | ✓ | | | |
| គោលការណ៍ទី២៤ ការបង្ហាញទិន្នន័យដោយមណ្ឌលទុកទិន្នន័យពាណិជ្ជកម្ម | | | | |

ដើម្បីបន្តពង្រឹងភាពធន់ ធានាវឌ្ឍនភាពនៃប្រព័ន្ធ តាមដាននិងវាយតម្លៃពីភាពរឹងមាំនិងកម្រិតនៃការអនុលោមតាមច្បាប់បទប្បញ្ញត្តិ ព្រមទាំងកែលម្អប្រព័ន្ធទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងស្របតាមនិន្នាការថ្មីៗនៃប្រព័ន្ធទូទាត់សងប្រាក់ក្នុងតំបន់និងសកលលោក ធនាគារជាតិនៃកម្ពុជាបានរៀបចំការត្រួតពិនិត្យ និងវាយតម្លៃថ្នាលធនាគារជាតិនៃកម្ពុជា ដែលជាហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុដ៏សំខាន់មួយ ត្រូវបានប្រើប្រាស់សម្រាប់ការដេញថ្លៃ ការចុះបញ្ជីមូលបត្រ ការជួញដូរមូលបត្ររដ្ឋ/រូបិយប័ណ្ណរវាងសមាជិកក្នុងថ្នាល ការរក្សាទុកមូលបត្រ ការទូទាត់

ប្រាក់ចំពោះប្រតិបត្តិការជួញដូរ និងចែករំលែកព័ត៌មានជូនសមាជិក ហើយចំពោះឧបករណ៍ហិរញ្ញវត្ថុដែលប្រើប្រាស់មានដូចជា មូលបត្រអាចជួញដូរបាន ប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា ប្រតិបត្តិការជួញដូររូបិយប័ណ្ណ និងឧបករណ៍ផ្ដល់សន្ទនីយភាពរយៈពេលខ្លី។ ការត្រួតពិនិត្យថ្នាលនេះ ធ្វើឡើងក្នុងគោលបំណងធ្វើឱ្យប្រព័ន្ធទូទាត់សងប្រាក់កាន់តែមានសុវត្ថិភាព ប្រសិទ្ធភាព និងប្រកបដោយនវានុវត្តន៍ និងកាត់បន្ថយហានិភ័យចម្បងៗ រួមមាន ហានិភ័យប្រតិបត្តិការ ហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ ហានិភ័យឥណទាន ហានិភ័យដួលរលំជាប្រព័ន្ធ និងហានិភ័យទីផ្សារប្ដូរប្រាក់ជាដើម។

## ៩.១.២. ការពិនិត្យ និងតាមដានប្រព័ន្ធទូទាត់សងប្រាក់

ប្រព័ន្ធទូទាត់សងប្រាក់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ ការទូទាត់ចំពោះការទិញ-លក់ទំនិញនិងសេវា និងការជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយប្រើប្រាស់នូវបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍសេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍។ ស្របតាមការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា និងតាមតម្រូវការទីផ្សារសេដ្ឋកិច្ចកម្ពុជា ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍនិងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចំនួន ២ រួមមាន ប្រព័ន្ធទូទាត់សងប្រាក់រួម និងប្រព័ន្ធធនាគារអេឡិចត្រូនិក។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើការពិនិត្យនិងតាមដានហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗជាប្រចាំ តាមរយៈការតាមដានប្រតិបត្តិការរបស់ប្រព័ន្ធនិងសិក្សាពីកំណើន និងនិន្នាការនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់នានា។

### ក. ប្រព័ន្ធទូទាត់សងប្រាក់រួម

ធនាគារជាតិនៃកម្ពុជា បានដាក់ប្រព័ន្ធទូទាត់សងប្រាក់រួមឱ្យដំណើរការសាកល្បងកាលពីពាក់កណ្ដាលឆ្នាំ២០២៤ និងមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកសរុបចំនួន ៧២ គ្រឹះស្ថាន ក្នុងនោះគ្រឹះស្ថានចំនួន ៥៦ បានដាក់ឱ្យដំណើរការសាកល្បង និង ១៦ គ្រឹះស្ថានផ្សេងទៀតកំពុងធ្វើសន្ធានកម្មប្រព័ន្ធ។ ប្រព័ន្ធទូទាត់សងប្រាក់រួម មានម៉ូឌុលចំនួន ២ ប្រភេទ ក្នុងនោះ ម៉ូឌុលបាគង មានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ និងម៉ូឌុលទូទាត់សុទ្ធ មានសេវាទូទាត់មូលប្បទានបត្រ និងសេវាបណ្ណទូទាត់។

ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការរបស់ប្រព័ន្ធទូទាត់សងប្រាក់រួម មានចំនួន ១,៣២ ប៊ីលានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ប្រមាណ ១.១៥២,៧ ទ្រីលានរៀល ឬស្មើនឹងប្រមាណ ២៨៥,៧ ប៊ីលានដុល្លារអាមេរិក ក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមានចំនួន ៧៧១,២៦ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ប្រមាណ ៣១៤,៤៩ ទ្រីលានរៀល និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៥៥,៥ លាន

ប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ប្រមាណ ២០៧,០៦ ប៊ីលានដុល្លារអាមេរិក។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមប្រព័ន្ធទូទាត់សងប្រាក់រួម មានទំហំប្រហែល ៥,៧ ដងនៃផ.ស.ស។

**ក្រាហ្វ ១ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់រួម**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### i - ម៉ូឌុលបាគង

ម៉ូឌុលបាគង ជាម៉ូឌុលមួយក្នុងប្រព័ន្ធទូទាត់សងប្រាក់រួមដែលផ្តល់សេវាទូទាត់អន្តរប្រតិបត្តិការភ្លាមៗ (Real-Time) រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការសរុបក្នុងម៉ូឌុលបាគងមានចំនួន ១,៣២ ប៊ីលានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ៩០៨,៦ ទ្រីលានរៀល (ស្មើនឹងប្រមាណ ២២៧,១៦ ប៊ីលានដុល្លារអាមេរិក)។ ក្នុងនោះ ប្រតិបត្តិការជាប្រាក់រៀលមានចំនួន ៧៧១,១៦ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ២៨៩,០៦ ទ្រីលានរៀល និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៥៤,៥ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ១៥៤,៩ ប៊ីលានដុល្លារអាមេរិក។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមម៉ូឌុលបាគងមានទំហំប្រហែល ៤,៥ ដងនៃផ.ស.ស។

**ក្រាហ្វ ២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃម៉ូឌុលបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **សេវាទូទាត់បាគង៖** សេវាទូទាត់បាគង ត្រូវបានអភិវឌ្ឍក្នុងគោលបំណងជំរុញអន្តរប្រតិបត្តិការ ផ្តល់ភាពងាយស្រួល និងសុវត្ថិភាពក្នុងការផ្ទេរប្រាក់រវាងគ្រឹះស្ថានផ្សេងគ្នា។ ការដាក់ឱ្យប្រើប្រាស់សេវាទូទាត់បាគងដោយមានមុខងារអន្តរប្រតិបត្តិការភ្លាមៗរវាងគ្រឹះស្ថានជាសមាជិកនិងកម្មវិធីទូរស័ព្ទចល័តនៅក្នុងថ្នាលតែមួយ បានចូលរួមកាត់បន្ថយកម្រៃប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពទូទាត់សងប្រាក់។ ម៉្យាងទៀត សេវាទូទាត់បាគងបានពង្រីកលទ្ធភាពដល់ប្រជាជនដែលពុំមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមរយៈការពង្រីកបណ្តាញឱ្យកាន់តែទូលំទូលាយ មានតម្លៃសមរម្យ និងផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់។ ក្នុងឆ្នាំ២០២៥ សេវាទូទាត់បាគង មានប្រតិបត្តិការសរុបចំនួន ១,៣២ ប៊ីលានប្រតិបត្តិការ (កើនឡើង ១,២ ដង) ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀលមាន ៧៧១,២ លានប្រតិបត្តិការ (កើនឡើង ១,៥ ដង) និងចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៥៥៤,៥ លានប្រតិបត្តិការ (កើនឡើង ៧៩,៧%)។ ទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់បាគងមានចំនួនសរុបប្រមាណ ៨៩៧,១៤ ទ្រីលានរៀល ឬស្មើប្រមាណ ២២៤,២៨ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៥២%) ដែលក្នុងនោះទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀលមានចំនួន ២៨៥,៩ ទ្រីលានរៀល (កើនឡើង ៥៩,៤%) និងទំហំប្រាក់ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៥២,៨ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៤៩,៣%)។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមសេវាទូទាត់បាគង មានទំហំប្រហែលនឹង ៤,៥ ដងនៃផ.ស.ស។

**ក្រាហ្វ ៣ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់បាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **សេវាទូទាត់បាគងតម្លៃធំ៖** សេវាទូទាត់បាគងតម្លៃធំ ជាសេវាទូទាត់ដែលត្រូវបានអភិវឌ្ឍក្នុងគោលបំណងរក្សាសុវត្ថិភាពស្ថិរភាព និងប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចដែលមានប្រតិបត្តិការតម្លៃធំ ជាពិសេសប្រតិបត្តិការទីផ្សារហិរញ្ញវត្ថុ។ ការដាក់ឱ្យប្រើប្រាស់សេវានេះនឹងលើកកម្ពស់ការទូទាត់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសផ្តល់នូវភាពងាយស្រួលសម្រាប់បុគ្គលនិងធុរជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុជាឌីជីថលដែលមានទំហំប្រតិបត្តិការធំៗ ក្នុងឆ្នាំ២០២៥ សេវាទូទាត់បាគងតម្លៃធំ មានប្រតិបត្តិការសរុបចំនួន ១២,៧ ពាន់ប្រតិបត្តិការ (កើនឡើង ២ ដង) ក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមានចំនួន ១,៦ ពាន់ប្រតិបត្តិការ (កើនឡើង ១,២ ដង) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១១,១ ពាន់ប្រតិបត្តិការ (កើនឡើង ២,៣ ដង)។ ចំពោះទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់បាគងតម្លៃធំ មានចំនួនសរុបប្រមាណ ១១,៥ ទ្រីលានរៀល (ស្មើប្រមាណ ២,៩ ប៊ីលានដុល្លារអាមេរិក) (កើនឡើងប្រមាណ ៣ ដង) ដែលក្នុងនោះទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀល មានចំនួនប្រមាណ ៣,១ ទ្រីលានរៀល (កើនឡើង ៧,៣ ដង) និងទំហំប្រាក់ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក មានចំនួនប្រមាណ ២,១ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២,៧ ដង)។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមសេវាទូទាត់បាគងតម្លៃធំ មានទំហំប្រហែលនឹង ៦% នៃផ.ស.ស។

**ក្រាហ្វ ៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ឆ្លងតម្លៃធំ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ii - ម៉ូឌុលទូទាត់សុទ្ធ

ម៉ូឌុលទូទាត់សុទ្ធ ជាម៉ូឌុលមួយក្នុងប្រព័ន្ធទូទាត់សងប្រាក់រួមដែលផ្តល់សេវាទូទាត់សុទ្ធរួមមានសេវាទូទាត់មូលប្បទានបត្រ និងសេវាបណ្ណទូទាត់។ ក្នុងឆ្នាំ២០២៥ ម៉ូឌុលទូទាត់សុទ្ធមានប្រតិបត្តិការសរុបចំនួន ១,១១ លានប្រតិបត្តិការ និងមានទំហំប្រាក់ប្រតិបត្តិការសរុបប្រមាណ ២៣៤ ទ្រីលានរៀល ឬស្មើប្រមាណ ៥៨,៥២ ប៊ីលានដុល្លារអាមេរិក។ ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀលមាន ១០៧ ពាន់ប្រតិបត្តិការ ដោយមានទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀលចំនួន ២៥,៤ ទ្រីលានរៀល។ រីឯចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ១,០១ លានប្រតិបត្តិការ ដោយមានទំហំប្រាក់ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥២,១៦ ប៊ីលានដុល្លារអាមេរិក។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមម៉ូឌុលទូទាត់សុទ្ធ មានទំហំប្រហែលនឹង ១,២ ដងនៃផ.ស.ស។

**ក្រាហ្វ ៥ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃម៉ូឌុលទូទាត់សុទ្ធ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **សេវាទូទាត់មូលប្បទានបត្រ៖** សេវាទូទាត់មូលប្បទាន សំដៅលើផ្នែកមួយនៃម៉ូឌុលទូទាត់សុទ្ធដែលផ្តល់សេវាផាត់ទាត់ និងទូទាត់មូលប្បទានបត្រ។ សេវាទូទាត់មូលប្បទានបត្រត្រូវបានបង្កើតឡើង ក្នុងគោលបំណងសម្រួលដល់ដំណើរការនៃការផាត់ទាត់ និងទូទាត់អន្តរធនាគារទាក់ទងនឹងមូលប្បទានបត្រដោយធានាថា មូលនិធិត្រូវបានផ្ទេរប្រកបដោយប្រសិទ្ធភាព និងភាពត្រឹមត្រូវ។ តាមរយៈសេវានេះ អតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់អាចធ្វើប្រតិបត្តិការទូទាត់តាមរយៈមូលប្បទានបត្រប្រកបដោយភាពងាយស្រួលកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់។ ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការសរុបក្នុងសេវាទូទាត់មូលប្បទានបត្រមានចំនួន ១,០២ លានប្រតិបត្តិការ (ថយចុះ ២,២%) ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀលមាន ៣០ ពាន់ប្រតិបត្តិការ (ថយចុះ ៧,៧%) និងចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៩៩៣ ពាន់ប្រតិបត្តិការ (ថយចុះ ២,១%)។ ចំពោះទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់មូលប្បទានបត្រមានចំនួនសរុបប្រមាណ ២៣៤ ទ្រីលានរៀល ឬស្មើប្រមាណ ៥៨,៥២ ប៊ីលានដុល្លារអាមេរិក (ថយចុះ ៧%) ក្នុងនោះទំហំប្រាក់ជាប្រាក់រៀលមានចំនួន ២៥,៤ ទ្រីលានរៀល (កើនឡើង ១៧,៤%) និងទំហំប្រាក់ជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥២,១៦ ប៊ីលានដុល្លារអាមេរិក (ថយចុះ ៩,៤%)។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមសេវាទូទាត់មូលប្បទានបត្រ មានទំហំប្រហែល ១,១ ដង នៃផ.ស.ស។

**ក្រាហ្វ ៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់មូលប្បទានបត្រ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**- សេវាបណ្ណទូទាត់៖** សេវាបណ្ណទូទាត់ សំដៅលើផ្នែកមួយនៃម៉ូឌុលទូទាត់សុទ្ធដែលផ្ដល់សេវាផាត់ទាត់ និងទូទាត់ប្រតិបត្តិការបណ្ណទូទាត់។ សេវាបណ្ណទូទាត់ជាស្វីចរបស់ប្រទេសកម្ពុជា អភិវឌ្ឍឡើងដើម្បីជាមធ្យោបាយងាយស្រួលសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកអាចធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានតាមបណ្ណទូទាត់ឥណពន្ធ លើគ្រប់ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាត។ ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការសរុបក្នុងសេវាបណ្ណទូទាត់មានចំនួន ៩០ ពាន់ប្រតិបត្តិការ (ថយចុះ ៥៤,២%) ដោយក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមានចំនួន ៧៦,៩ ពាន់ប្រតិបត្តិការ (ថយចុះ ៥៣,១%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៣,៧ ពាន់ប្រតិបត្តិការ (ថយចុះ ៥៩,៥%)។ រីឯទំហំប្រាក់ប្រតិបត្តិការនៃសេវាបណ្ណទូទាត់មានចំនួនសរុប ២៦,១២ ប៊ីលានរៀល ឬស្មើប្រមាណ ៦,៥៣ លានដុល្លារអាមេរិក (ថយចុះ ៥១%) ក្នុងនោះទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀលមានចំនួន ១៨,៧ ប៊ីលានរៀល (ថយចុះ ៤៧,៥%) និងទំហំប្រាក់ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១,៩ លានដុល្លារអាមេរិក (ថយចុះ ៥៨,៥%)។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមសេវាបណ្ណទូទាត់ មានទំហំប្រមាណ ០,០១% នៃផ.ស.ស។

**ក្រាហ្វ ៧ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាបណ្ណទូទាត់ CSS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. ប្រព័ន្ធធនាគារអេឡិចត្រូនិក

គិតត្រឹមឆ្នាំ២០២៥ ប្រព័ន្ធធនាគារអេឡិចត្រូនិកមានសមាជិកសរុបចំនួន ៨៧ គ្រឹះស្ថាន ដែលក្នុងនោះមានធនាគារពាណិជ្ជចំនួន ៥៧ ធនាគារឯកទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១៨ និងស្ថាប័នរដ្ឋចំនួន ២ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ក្នុងឆ្នាំ២០២៥ ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអេឡិចត្រូនិក មានប្រតិបត្តិការសរុប ៩២,៩ ពាន់ប្រតិបត្តិការ និងមានទំហំប្រាក់ប្រមាណ ៦២២,៣ ទ្រីលានរៀល ឬស្មើប្រមាណ ១៥៥,៦ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២២,៦%)។ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលមានចំនួនប្រមាណ ៩១,៨ ពាន់ប្រតិបត្តិការ កើនឡើង ១២% និងមានទំហំប្រាក់ ៦២៤,៩ ទ្រីលានរៀល ឬស្មើប្រមាណ ១៥៥,៩ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២២%) ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀលមាន ៥៩,៤ ពាន់ប្រតិបត្តិការ កើនឡើង ១៣% ដែលមានទំហំប្រាក់ ១៦១,៨ ទ្រីលានរៀល កើនឡើង ២១,៦% និងចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣២,៤ ពាន់ប្រតិបត្តិការ កើនឡើង ៩,៥% និងមានទំហំប្រាក់ ១០៥,៥ ប៊ីលានដុល្លារអាមេរិក កើនឡើង ២២,៩%។ រីឯ

ប្រតិបត្តិការផ្ទេរប្រាក់ជាមួយសាខាធនាគារជាតិនៃកម្ពុជាមានចំនួន ១០៩០ ប្រតិបត្តិការ កើនឡើង ៣៧,៥% និងមានទំហំប្រាក់ ២៧,៤ ទ្រីលានរៀល ឬស្មើប្រមាណ ៦,៨ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២២,៥%) ក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀលមាន ៧០៧ ប្រតិបត្តិការ កើនឡើង ៧៥% និងមានទំហំប្រាក់ប្រតិបត្តិការចំនួន ៨,២ ទ្រីលានរៀល កើនឡើង ៣២,២% និងចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៣៨៣ ប្រតិបត្តិការ កើនឡើង ៤,៦% និងមានទំហំប្រាក់ ៤,៨ ប៊ីលានដុល្លារអាមេរិក កើនឡើង ២០,៥%។ ទំហំប្រាក់ប្រតិបត្តិការសរុបតាមប្រព័ន្ធធនាគារអេឡិចត្រូនិកនៅក្នុងឆ្នាំ២០២៥ ស្មើនឹងប្រមាណ ៣ ដង នៃផ.ស.ស។

**ក្រាហ្វ ៨ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធធនាគារអេឡិចត្រូនិក**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤.២. ការត្រួតពិនិត្យសេវាទូទាត់សងប្រាក់

### ៤.២.១. ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានធ្វើឡើងជាប្រចាំ ទាំងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង តាមរយៈការវិភាគស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថាននីមួយៗ សំដៅកំណត់ឱ្យបានជាមុននូវហានិភ័យនានា និងចាត់វិធានការកែតម្រូវទាន់ពេលវេលា។ ក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់

សងប្រាក់ចំនួន ៦ (ស្របទៅតាមផែនការចុះត្រួតពិនិត្យដល់ទីកន្លែងសម្រាប់ឆ្នាំ២០២៥) ដោយផ្តោតលើអភិបាលកិច្ច ហានិភ័យផ្សេងៗដូចជា ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការ និងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងយន្តការការពារផលប្រយោជន៍អតិថិជន។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បានវិភាគពីស្ថានភាពរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ផ្អែកលើអនុបាតមួយចំនួនដូចជា អនុបាតសន្ទនីយភាព អនុបាតលទ្ធភាពស្វែងរកប្រាក់ចំណេញ និងភាពគ្រប់គ្រាន់នៃដើមទុន។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ និងផ្លាស់ប្តូរទីតាំងថ្មីចំនួន ៦ គ្រឹះស្ថានបន្ថែមទៀត។

### ៤.២.២. ប្រតិបត្តិការសេវាទូទាត់សងប្រាក់

ការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល និងការគាំទ្រពីគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា បានជំរុញឱ្យសេវាទូទាត់សងប្រាក់កាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពកាន់តែខ្ពស់។ គិតត្រឹមឆ្នាំ២០២៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាមានចំនួន ៣០ គ្រឹះស្ថាន ដែលបាននិងកំពុងធ្វើប្រតិបត្តិការយ៉ាងសកម្ម។ ចំនួនគណនីរូបិយវត្ថុអេឡិចត្រូនិកមានសរុប ១៧,៨៩ លានគណនី (ថយចុះ ១៣,៤%) ខណៈដែលចំនួនភ្នាក់ងារផ្តល់សេវាទូទាត់សងប្រាក់មានចំនួនប្រមាណ ៣៧ ពាន់ទីតាំង។

**ក្រាហ្វ ៩ - ចំនួនភ្នាក់ងារ អតិថិជនមានគណនីរូបិយវត្ថុអេឡិចត្រូនិក និងអតិថិជន Walk-in របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំពោះមូលនិធិដែលទទួលបានពីអតិថិជនតាមរយៈការធ្វើប្រតិបត្តិការសេវាទូទាត់ចល័ត គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានរក្សាទុកនៅក្នុងគណនីអាណត្តិព្យាបាលដែលមានជាមួយគ្រឹះស្ថានធនាគារពាណិជ្ជ។ គិតត្រឹមឆ្នាំ២០២៥ សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានចេញផ្សាយកើនដល់ចំនួន ៣,២៩ ទ្រីលានរៀល ឬស្មើប្រមាណ ៨២២,១៩ លានដុល្លារអាមេរិក និងសមតុល្យដែលបានរក្សាទុកក្នុងគណនីអាណត្តិព្យាបាល[១] បានកើនឡើងដល់ ៣,៣១ ទ្រីលានរៀល ឬស្មើប្រមាណ ៨២៨,៥២ លានដុល្លារអាមេរិក។

**ក្រាហ្វ ១០ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការសេវាទូទាត់ចល័តតាមគណនីរូបិយវត្ថុអេឡិចត្រូនិកមានចំនួន ២.១៦៧,០៨ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ៦៧៩,៩៩ ទ្រីលានរៀល ឬស្មើប្រមាណ ១៧០ ប៊ីលានដុល្លារអាមេរិក។ ក្នុងនោះ ប្រតិបត្តិការជាប្រាក់រៀលមានចំនួន ១.១៨៩,៥៧ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ២៨៦,៩១ ទ្រីលានរៀល និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៩៧៧,៥១ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ៩៨,២៧ ប៊ីលានដុល្លារអាមេរិក។

(១) គណនីអាណត្តិព្យាបាល សំដៅដល់គណនីដែលបើកដោយអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក នៅពេលទទួលសាច់ប្រាក់ពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ រក្សាទុកក្នុងធនាគារអាណត្តិព្យាបាលមួយ ឬច្រើន (ធនាគារពាណិជ្ជ) ក្នុងគោលបំណងធ្វើប្រតិបត្តិការទូទាត់សងប្រាក់តែមួយគត់ ដែលបញ្ជាដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងមិនត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកឡើយ។

**ក្រាហ្វ ១១ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័ត**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹមឆ្នាំ២០២៥ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់សេវាធនាគារចល័តមានចំនួន ៤៣ គ្រឹះស្ថាន និងផ្តល់សេវាធនាគារអ៊ីនធឺណិតចំនួន ៤២ គ្រឹះស្ថាន។ ចំនួនប្រតិបត្តិការតាមសេវាធនាគារចល័តសរុបមាន ១.៥៧៦,៦៩ លានប្រតិបត្តិការ ដោយក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមាន ៣៨០,៣២ លានប្រតិបត្តិការ និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ១.១៩៦,៣៧ លានប្រតិបត្តិការ និងមានទំហំប្រាក់សរុបចំនួន ១.០៤៥,០១ ទ្រីលានរៀល ឬស្មើប្រមាណ ២៦១,២៥ ប៊ីលានដុល្លារអាមេរិក។ ខណៈដែលចំនួនប្រតិបត្តិការតាមសេវាអ៊ីនធឺណិតសរុបមាន ២០,៤៣ លានប្រតិបត្តិការ ក្នុងនោះមានប្រតិបត្តិការជាប្រាក់រៀលមាន ២,៥០ លានប្រតិបត្តិការ និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក មាន ១៧,៩៣ លានប្រតិបត្តិការ និងមានទំហំប្រាក់សរុប ១៤៧ ទ្រីលានរៀល ឬស្មើប្រមាណ ៣៦,៧៥ ប៊ីលានដុល្លារអាមេរិក។ តាមរយៈទិន្នន័យខាងលើនេះ បានបង្ហាញថា ប្រជាពលរដ្ឋបានផ្លាស់ប្តូរទំនោរងាកទៅប្រើប្រាស់សេវាធនាគារចល័ត និងសេវាធនាគារអ៊ីនធឺណិតកាន់តែច្រើន ក្នុងការទូទាត់ផ្សេងៗជំនួសឱ្យការប្រើប្រាស់សាច់ប្រាក់។

### ក្រាហ្វ ១២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាធនាគារចល័ត




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ១៣ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាធនាគារអ៊ីនធឺណិត




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បណ្ណទូទាត់នៅតែជាឧបករណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់ការទូទាត់តម្លៃរាយ និងតាមប្រព័ន្ធអនឡាញ។ គិតត្រឹមឆ្នាំ២០២៥ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤៣ បានចេញផ្សាយបណ្ណទូទាត់ដែលមានចំនួនសរុបប្រមាណ ៧,០២ លានបណ្ណ ក្នុងនោះបណ្ណឥណពន្ធមានចំនួន ២,៣៧ លានបណ្ណ បណ្ណឥណទានមានចំនួន ០,២៩ លានបណ្ណ បណ្ណបង់ប្រាក់ជាមុនមានចំនួន ១,៦៤ លានបណ្ណ និងបណ្ណដក/ដាក់ប្រាក់មានចំនួន ២,៧២ លានបណ្ណ។ ប្រតិបត្តិការទូទាត់តាមបណ្ណទូទាត់ក្នុងស្រុកមានការថយចុះ ១៦,៥% ពី ១៤៧,៤២ មកត្រឹម ១២៣,១៣ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ៩១,៩៤ ទ្រីលានរៀល ឬស្មើប្រមាណ ២២,៩៩ ប៊ីលានដុល្លារអាមេរិក។ ដោយឡែក ប្រតិបត្តិការតាមបណ្ណទូទាត់នៅក្រៅប្រទេសមានការកើនឡើង ២៦,២% ពី ៣,១១ ទៅ ៣,៩៣ លានប្រតិបត្តិការ និងមានទំហំប្រាក់ ៥,០៧ ទ្រីលានរៀល ឬស្មើប្រមាណ ១,២៧ ប៊ីលានដុល្លារអាមេរិក។ ចំណែកឯប្រតិបត្តិការបណ្ណទូទាត់តាមអនឡាញមានការកើនឡើង ១៥,៨% ពី ៣៤,១ ទៅ ៣៩,៤៧ លានប្រតិបត្តិការ និងមានទំហំប្រាក់ ៨,១៤ ទ្រីលានរៀល ឬស្មើប្រមាណ ២,០៤ ប៊ីលានដុល្លារអាមេរិក។

**ក្រាហ្វ ១៤ - ចំនួនបណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងបណ្ណទូទាត់អន្តរជាតិ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រៅពីសេវាធនាគារឌីជីថល បណ្ដាញទូទាត់តាមម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាត ក៏ជាមធ្យោបាយជួយសម្រួលដល់លទ្ធភាពទទួលបានសាច់ប្រាក់ និងទូទាត់ផ្សេងៗឱ្យកាន់តែងាយស្រួល និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ទាំងមូលផងដែរ។ គិតត្រឹមឆ្នាំ២០២៥ ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិត្រូវបានតម្លើងសរុបមានចំនួន ៥,៧៤ ពាន់គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន ៥២,២៨ ពាន់គ្រឿង នៅទូទាំងប្រទេសកម្ពុជា។

**ក្រាហ្វ ១៥ - ចំនួនម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាត**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការទូទាត់តាមឃ្យូអរកូដ នៅតែជាមធ្យោបាយដែលមានប្រជាប្រិយភាព ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារខេអេចឃ្យូអរកូដ ដែលបានសម្រួលដល់ការទូទាត់អន្តរគ្រឹះស្ថាន ព្រមទាំងការទូទាត់ឆ្លងដែនជាមួយប្រទេសនៅក្នុងតំបន់។ តាមរយៈក្រាហ្វខាងក្រោម បានបង្ហាញអំពីប្រតិបត្តិការទូទាត់តាមឃ្យូអរកូដដែលមានចំនួន ១.៨៨៩,៣ លានប្រតិបត្តិការ (កើនឡើង ១៣៦,៥%) ដោយក្នុងនោះទំហំប្រាក់មានចំនួន ៤២២,៩៨ ទ្រីលានរៀល ឬស្មើប្រមាណ ១០៥,៦២ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ២,៥ ដង នៃផ.ស.ស។

**ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាមឃ្យូអរកូដ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ ៤ - ការផ្តល់សេវាពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ

ដោយពិនិត្យឃើញពីការវិវត្តឥតឈប់ឈរនៃទ្រព្យសកម្មគ្រីបតូ ជាពិសេសហានិភ័យប្រឈមនានាដែលអាចប៉ះពាល់ដល់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ក្នុងគោលបំណងគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការ ក៏ដូចជាអាជីវកម្មពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ស្របតាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩។ ប្រកាសនេះ បានបែងចែកជាពីរផ្នែក ដែលផ្នែកទី១ កំណត់អំពីប្រភេទទ្រព្យសកម្មគ្រីបតូ និងអ៊ិចស្តូស៊ើ សម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងផ្នែកទី២ កំណត់អំពីនីតិវិធីក្នុងការស្នើសុំអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត។ គិតត្រឹមឆ្នាំ២០២៥ ពុំទាន់មានគ្រឹះស្ថានណាមួយទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ក្នុងការធ្វើប្រតិបត្តិការពាក់ព័ន្ធទ្រព្យសកម្មគ្រីបតូនៅឡើយទេ។

ទោះជាយ៉ាងណា ការកំណត់ដែនសមត្ថកិច្ចនៃអាជ្ញាធរគ្រប់គ្រងទ្រព្យសកម្មគ្រីបតូនៅមានភាពមិនច្បាស់លាស់ និងប្រទាក់ក្រឡាគ្នាខ្លាំង ដែលទាមទារឱ្យមានការពិភាក្សានិងសហការគ្នារវាងអាជ្ញាធរពាក់ព័ន្ធ។ ការណ៍នេះ ធនាគារជាតិនៃកម្ពុជា កំពុងសហការគ្នាជាមួយនិយ័តករមូលបត្រកម្ពុជា រៀបចំគោលការណ៍ណែនាំរួមស្តីពី គោលការណ៍នៃការគ្រប់គ្រងទ្រព្យសកម្មគ្រីបតូ និងក្រុមហ៊ុនផ្តល់សេវាទ្រព្យសកម្មគ្រីបតូ ដើម្បីណែនាំអំពីក្របខណ្ឌបទប្បញ្ញត្តិដែលអនុវត្តចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលផ្តល់សេវាទ្រព្យសកម្មគ្រីបតូ ឬផ្តល់សេវាពាក់ព័ន្ធនឹងទ្រព្យនិម្មិតដល់រូបវន្តបុគ្គល ឬនីតិបុគ្គលនៅកម្ពុជា។ គោលការណ៍ណែនាំរួមនេះ បានកំណត់អំពីដែនសមត្ថកិច្ចរបស់ស្ថាប័ននីមួយៗ ដោយការប្រើប្រាស់ទ្រព្យសកម្មគ្រីបតូសម្រាប់ជាមធ្យោបាយទូទាត់សងប្រាក់ ស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា រីឯការប្រើប្រាស់ទ្រព្យសកម្មគ្រីបតូសម្រាប់ជាមធ្យោបាយក្នុងការវិនិយោគ ស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់និយ័តករមូលបត្រកម្ពុជា។ បន្ទាប់ពីការដាក់ចេញគោលការណ៍ណែនាំរួមនេះ ធនាគារជាតិនៃកម្ពុជានឹងធ្វើការរៀបចំសេចក្តីព្រាងប្រកាសស្តីពី នីតិវិធីផ្តល់លិខិតអនុញ្ញាតសម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីផ្តល់សេវាទូទាត់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មគ្រីបតូ ជាមធ្យោបាយនៃការទូទាត់ដល់អតិថិជន ស្របតាមលក្ខខណ្ឌនៃប្រកាសស្តីពីប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ។

# ៥. ចំណេះដឹងហិរញ្ញវត្ថុឌីជីថល

ការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា បានរួមចំណែកក្នុងការពន្លឿននវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន តាមរយៈការផ្តល់នូវផលិតផល និងសេវាថ្មីៗសម្រាប់អ្នកប្រើប្រាស់ដែលបានជួយសម្រួលនិងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទោះបីជាយ៉ាងណាបច្ចេកវិទ្យាទាំងនេះ ក៏អាចបង្កជាហានិភ័យដែលពុំអាចមើលរំលងបាន ដូចជាឯកជនភាពទិន្នន័យ ការគំរាមកំហែងសន្តិសុខសាយប័រ និងការពុំទាន់យល់ច្បាស់អំពីការប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញវត្ថុជាដើម។

## ៥.១. កិច្ចការពារអតិថិជន

ដើម្បីចូលរួមដោះស្រាយបញ្ហារបស់អតិថិជន ក្នុងការប្រើប្រាស់សេវានិងផលិតផលហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ធនាគារជាតិនៃកម្ពុជាបានពិនិត្យ និងកែសម្រួលប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលដៅពង្រឹងយន្តការគ្រប់គ្រង និងដោះស្រាយបណ្តឹងអតិថិជនឱ្យស្របតាមច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងការវិវត្តនៃប្រព័ន្ធធនាគារ។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវសេចក្តីណែនាំមួយចំនួនដូចជា (១) សេចក្តីណែនាំស្តីពី ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការទូទាត់សងប្រាក់នៅកម្ពុជានិងប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែន កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ ដើម្បីផ្សព្វផ្សាយនិងបន្តជំរុញការអនុវត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យយកចិត្តទុកដាក់ក្នុងការបង្ការ ទប់ស្កាត់ និងដោះស្រាយលើប្រតិបត្តិការក្លែងបន្លំ ឬវិវាទប្រតិបត្តិការដែលពាក់ព័ន្ធនឹងការទូទាត់សងប្រាក់នៅកម្ពុជានិងការទូទាត់ឆ្លងដែន (២) សេចក្តីណែនាំស្តីពី ការលើកកម្ពស់ការទូទាត់តាមខេអេចឃ្យូអរកូតសម្រាប់ពាណិជ្ជករ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់ការទូទាត់សងប្រាក់តាមរយៈខេអេចឃ្យូអរកូត ផ្តល់ភាពងាយស្រួលដល់អាជីវករ ឬពាណិជ្ជករដែលទទួលការទូទាត់ពីភ្ញៀវទេសចរ និងដើម្បីពង្រីកកិច្ចសហការទូទាត់ឆ្លងដែនកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព និង (៣) សេចក្តីណែនាំស្តីពី ការពង្រឹងនីតិវិធីនៃការជូនដំណឹងអំពីភាពរអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ជូនដល់សាធារណជន កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយខ្លឹមសារនៃសេចក្តីណែនាំនេះ តម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជូនដំណឹងពីរបាយការណ៍ឧប្បត្តិហេតុព័ត៌មានវិទ្យា បញ្ហារអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់តាមកម្មវិធីធនាគារចល័ត/កម្មវិធីទូទាត់ចល័ត និងបណ្តាញសេវាធនាគារនានា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការទូទាត់សងប្រាក់របស់សាធារណជន ដើម្បីផ្តល់លទ្ធភាពឱ្យធនាគារជាតិនៃកម្ពុជាតាមដាន សម្របសម្រួល និងដោះស្រាយបញ្ហាឱ្យទាន់ពេលវេលា។

ដើម្បីរួមចំណែកបង្កើនជំនឿទុកចិត្តរបស់សាធារណជន ក៏ដូចជាចូលរួមទប់ស្កាត់បទល្មើសឆបោកដោយប្រើប្រាស់គណនីធនាគារ ឬគណនីទូទាត់សងប្រាក់ តាមរយៈលេខទូរសព្ទដែលពុំមានអត្តសញ្ញាណត្រឹមត្រូវ ឬបន្លំអត្តសញ្ញាណ និងដើម្បីជំរុញការធ្វើបរិវត្តកម្ម និងនវានុវត្តន៍ឌីជីថលនៅក្នុងវិស័យធនាគារ និងវិស័យទូរគមនាគមន៍ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមរយៈការចុះអនុស្សរណៈយោគយល់ស្ដីពី កិច្ចសហប្រតិបត្តិការលើការជំរុញបរិវត្តកម្មឌីជីថល និងការផ្ទៀងផ្ទាត់អត្តសញ្ញាណស៊ីមកាតជាមួយនឹងគណនីធនាគារ/គណនីទូទាត់សងប្រាក់របស់អ្នកប្រើប្រាស់ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥។ កិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាសក្ខីភាពនៃការប្ដេជ្ញាចិត្តរវាងស្ថាប័នទាំងពីរក្នុងការជំរុញបរិវត្តកម្មឌីជីថល ដែលនឹងរួមចំណែកការពារផលប្រយោជន៍អតិថិជនជំរុញនវានុវត្តន៍លើការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុប្រកបដោយជំនឿទុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្ន ព្រមទាំងផ្ដល់ជាកាលានុវត្តភាពរវាងគ្នា សំដៅគាំទ្រដល់ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាប្រកបដោយនិរន្តរភាព ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល។ គម្រោងនៃកិច្ចសហប្រតិបត្តិការនេះ គ្រោងនឹងដាក់ឱ្យដំណើរការជា ២ ដំណាក់កាល ដែលដំណាក់កាលទី១ នឹងអនុវត្តជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួននៅកម្ពុជា និងដំណាក់កាលទី២ នឹងអនុវត្តជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត។





*ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្ដីពី "កិច្ចសហប្រតិបត្តិការលើការជំរុញបរិវត្តកម្មឌីជីថល និងការផ្ទៀងផ្ទាត់អត្តសញ្ញាណស៊ីមកាតជាមួយនឹងគណនីធនាគារ / គណនីទូទាត់សងប្រាក់របស់អ្នកប្រើប្រាស់" នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា*

## ៥.២. ភាពធន់សុវត្ថិភាពសាយប័រ

ឌីជីថលភាវូបនីយកម្មនៅកម្ពុជា បានបន្តវិវត្តគួរឱ្យកត់សម្គាល់ និងកំពុងដើរតួនាទីជាមូលដ្ឋានគ្រឹះដ៏សំខាន់ ព្រមទាំងរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាពក្នុងការជំរុញការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ជាពិសេសវិស័យហិរញ្ញវត្ថុ។ ទោះជាយ៉ាងណា ភាពពេញនិយមនៃឧបករណ៍ឌីជីថល ប្រព័ន្ធអ៊ីនធឺណិត និង/ឬប្រព័ន្ធផ្សព្វផ្សាយឌីជីថលផ្សេងៗ ក៏នាំមកនូវបញ្ហាប្រឈមថ្មីៗផងដែរ ពោលគឺបញ្ហាសន្តិសុខនៅក្នុងវិស័យឌីជីថល។

ស្របពេលដែលសេវាហិរញ្ញវត្ថុឌីជីថល បាននិងកំពុងរីកម្រើនយ៉ាងឆាប់រហ័ស និងបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អតិថិជន ប៉ុន្តែបច្ចេកវិទ្យាហិរញ្ញវត្ថុដែលត្រូវបានយកមកប្រើប្រាស់ក្នុងសេវាទាំងនេះក៏អាចផ្សារភ្ជាប់មកជាមួយនូវហានិភ័យពាក់ព័ន្ធផ្សេងៗ ដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អ្នកប្រើប្រាស់ និងអ្នកផ្តល់សេវា។ ដើម្បីបង្ការនូវហានិភ័យសន្តិសុខសាយប័រ ពង្រឹងកិច្ចការពារអតិថិជន និងបង្កើនទំនុកចិត្តលើសេវាហិរញ្ញវត្ថុឌីជីថល ព្រមទាំងលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុឌីជីថលឱ្យមានសុវត្ថិភាព និងនិរន្តរភាព ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័រសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត។ គោលការណ៍ណែនាំនេះ ឆ្លុះបញ្ចាំងអំពីការវិវត្តនៃការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិត ការកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងការពឹងផ្អែកកាន់តែខ្លាំងលើការប្រើសេវាហិរញ្ញវត្ថុឌីជីថលដូចជា សេវាធនាគារចល័ត សេវាធនាគារតាមអ៊ីនធឺណិត កាបូបអេឡិចត្រូនិក និងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក។ ជាមួយគ្នានោះ គោលការណ៍ខាងលើក៏បានរំលេចពីចំណុចគន្លឹះនៃការគ្រប់គ្រងហានិភ័យសាយប័រសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការពង្រឹងគណនេយ្យភាព និងភាពចាំបាច់លើអភិបាលកិច្ចសន្តិសុខសាយប័រ ការការពារទិន្នន័យ និងការការពារប្រព័ន្ធព័ត៌មានវិទ្យា ការគ្រប់គ្រងហានិភ័យពីអ្នកផ្តល់សេវាតតិយភាគី ការរៀបចំផែនការនិរន្តរភាពអាជីវកម្ម និងនីតិវិធីឆ្លើយតបចំពោះឧប្បត្តិហេតុដែលអាចនឹងកើតមានឡើង ការលើកកម្ពស់ការយល់ដឹងនិងសមត្ថភាពបុគ្គលិកអំពីហានិភ័យសាយប័រដើម្បីកំណត់យុទ្ធសាស្ត្រគោលនយោបាយ និងការត្រួតពិនិត្យការអនុវត្តសន្តិសុខសាយប័រ ព្រមទាំងគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័រ ប្រកបដោយប្រសិទ្ធភាព ធានាបាននូវសុវត្ថិភាព ស្ថិរភាព និងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។

## ៥.៣. ចំណេះដឹងហិរញ្ញវត្ថុឌីជីថល

### ៥.៣.១. ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ

ការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ ជាការងារអាទិភាពមួយដែលធនាគារជាតិនៃកម្ពុជាតែងតែយកចិត្តទុកដាក់ជាប្រចាំ ដើម្បីលើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលមានតម្លៃសមរម្យ និងមានការការពារតាមច្បាប់សម្រាប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជននៅតំបន់ជនបទ ដែលការយល់ដឹងផ្នែកសេវាហិរញ្ញវត្ថុឌីជីថលនៅមានកម្រិត។

ក្នុងគោលដៅលើកកម្ពស់ និងជំរុញការចាប់យកសេវាទូទាត់ឌីជីថល និងបង្ការ ក៏ដូចជាទប់ស្កាត់ការឆបោកក្នុងការប្រើប្រាស់សេវាទូទាត់ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាបន្តបន្ទាប់។ ក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានចូលរួមផ្សព្វផ្សាយ និងចែករំលែក ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល នៅក្នុងកម្មវិធីចែករំលែកចំណេះដឹងស្តីពី ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ ជូនមន្ត្រី-បុគ្គលិកសាខាធនាគារជាតិនៃកម្ពុជា និងសិស្ស-និស្សិតនៅតាមបណ្តាសាកលវិទ្យាល័យមួយចំនួននៅខេត្តព្រះសីហនុ កំពង់ចាម បាត់ដំបង សៀមរាប ក្រចេះ កំពង់ស្ពឺ និងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុបប្រមាណ ៥.២០០ នាក់។

សិក្ខាសាលាផ្សព្វផ្សាយខាងលើ រៀបចំឡើងតាមរយៈការធ្វើបទបង្ហាញអំពី ទិដ្ឋភាពទូទៅនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ជាពិសេសការអភិវឌ្ឍប្រព័ន្ធបាគង  ការទូទាត់និងផ្ទេរប្រាក់ឆ្លងដែន និងការទូទាត់សងប្រាក់តាមឌីជីថល ដែលឆ្លុះបញ្ចាំងពីកាលានុវត្តន៍ភាពថ្មីៗ និងគំនិតផ្តួចផ្តើមផ្សេងទៀតរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ។ ជាមួយគ្នានោះ ក៏មានជាការរៀបចំស្តង់ពិព័រណ៍អំពីប្រព័ន្ធបាគង និងការការពារពីការក្លែងបន្លំការទូទាត់ ដើម្បីជំរុញការផ្សព្វផ្សាយ និងការយល់ដឹងដល់សាធារណជន អំពីសារៈសំខាន់នៃការការពារព័ត៌មានផ្ទាល់ខ្លួន វិធីសាស្ត្រក្នុងទប់ស្កាត់ការក្លែងបន្លំការទូទាត់ដែលជនខិលខូចប្រើប្រាស់កន្លងមក  និងដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។ ជាមួយគ្នានោះ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការទទួលបានអត្ថប្រយោជន៍ពីការទូទាត់បែបឌីជីថលដែលមានលក្ខណៈងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព ធនាគារជាតិនៃកម្ពុជា បានផលិតជាវីឌីអូខ្លីៗ និងរៀបចំស្តង់ពិព័រណ៍ផ្សព្វផ្សាយអំពីប្រព័ន្ធបាគង និងបាគងយុវ័ន ជាបន្តបន្ទាប់ក្នុងកម្មវិធីនានា ព្រមទាំងបានចុះផ្សព្វផ្សាយបញ្ជ្រាបការប្រើប្រាស់កម្មវិធីទាំងនោះដល់សាធារណជន ជាពិសេសសិស្សានុសិស្សនៅតាមវិទ្យាល័យមួយចំនួន។










*សិក្ខាសាលាផ្សព្វផ្សាយអំពីប្រព័ន្ធបាគង សេវាទូទាត់សងប្រាក់ និងចំណេះដឹងហិរញ្ញវត្ថុឌីជីថល ក្នុងកម្មវិធីចែករំលែកចំណេះដឹង ស្តីពី "ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ" នៅតាមបណ្តាខេត្ត*

### ៥.៣.២. កិច្ចសហការការចែករំលែកចំណេះដឹងជាមួយនឹងបណ្តាធនាគារកណ្តាល

- **ធនាគាររដ្ឋប៉ាគីស្ថាន**



កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យគណៈ-ប្រតិភូធនាគាររដ្ឋប៉ាគីស្ថាន និងក្រុមហ៊ុន SORAMITSU Holdings AG. ចូលជួបពិភាក្សាការងារ ក្នុងគោលបំណងស្វែងរកលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋប៉ាគីស្ថាន ក៏ដូចជាផ្តល់ឱកាសឱ្យគណៈប្រតិភូបានស្វែងយល់អំពីប្រតិបត្តិការប្រព័ន្ធទូទាត់បាគង ស្របពេលដែលធនាគាររដ្ឋប៉ាគីស្ថានកំពុងរៀបចំអភិវឌ្ឍរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល។

- **អាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់**

កាលពីថ្ងៃទី១២ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៥ មន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់និងទុនបម្រុងរបស់អាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់ចំនួន ៦រូប បានអញ្ជើញមកធ្វើទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងស្វែងយល់ទៅលើ (១) លំហូរការងារដែលពាក់ព័ន្ធទៅនឹងគំរូនៃការអនុវត្តការគ្រប់គ្រងទុនបម្រុង រួមមាន អភិបាលកិច្ច ការគ្រប់គ្រងហានិភ័យនិងយុទ្ធសាស្ត្របែងចែកទ្រព្យសកម្ម (២) ប្រតិបត្តិការនិងឧត្តមានុវត្តន៍ក្នុងការផ្ទេរប្រាក់ឆ្លងដែនប្រកបដោយប្រសិទ្ធភាព (៣) ការផ្តល់អាជ្ញាបណ្ណអាជីវកម្មប្តូរប្រាក់ (៤) ការទូទាត់ឆ្លងរូបិយប័ណ្ណ (៥) ការទូទាត់ឆ្លងដែន និង (៦) គោលនយោបាយទីផ្សាររូបិយវត្ថុ។ ជាមួយគ្នានេះ មន្ត្រីនៃធនាគារជាតិនៃកម្ពុជាក៏បានចែករំលែកបទពិសោធន៍តាមប្រព័ន្ធអនឡាញអំពីដំណើរការនៃកម្មវិធីបាគងទេសចរផងដែរ។

- **ធនាគារកណ្តាលទីម័រខាងកើត**

កាលពីថ្ងៃទី២ ដល់ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥ មន្ត្រីជំនាញនៃធនាគារកណ្តាលទីម័រខាងកើតបានមកបំពេញទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងស្វែងយល់បន្ថែមទៅលើបទពិសោធន៍របស់ធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំផែនការ និងការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់បាគង ស្របពេលដែលធនាគារកណ្តាលទីម័រខាងកើតបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រឆ្នាំ២០២៥-២០៣៥ ដែលក្នុងចំណោមយុទ្ធសាស្ត្រអាទិភាពក៏មានពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការរូបិយប័ណ្ណឌីជីថលធនាគារកណ្តាលផងដែរ។

- **ធនាគារកណ្ដាលបង់ក្លាដេស**

កាលពីថ្ងៃទី៤ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៥ មន្ត្រីជំនាញនៃធនាគារកណ្ដាលបង់ក្លាដេស ចំនួន ៦ រូប បានអញ្ជើញមកបំពេញទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងសិក្សាស្វែងយល់អំពី យុទ្ធសាស្ត្រ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជាឆ្ពោះទៅកាន់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់សហគ្រាសធុន តូច និងមធ្យម។

- **ធនាគារកណ្ដាលនេប៉ាល់**

កាលពីថ្ងៃទី១០ ដល់១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមការងារធនាគារជាតិនៃកម្ពុជាបានចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់មន្ត្រីតំណាងធនាគារកណ្ដាលនេប៉ាល់ដែលបានមកទស្សនកិច្ចសិក្សាដោយផ្ទាល់អំពីប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា នៅធនាគារជាតិនៃកម្ពុជា ព្រមទាំងធ្វើទស្សនកិច្ចនៅសារមន្ទីរព្រះស្រីល្បសានវន្តនៃផងដែរ។ លើសពីនេះ កាលពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៥ មន្ត្រីតំណាងធនាគារកណ្ដាលនេប៉ាល់មួយក្រុមទៀត ក៏បានបន្តមកសិក្សាស៊ីជម្រៅបន្ថែមលើការងារបច្ចេកទេស រួមមាន ការគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធបាគង ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិ និងការអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

- **ធនាគារកណ្ដាលរវ៉ាន់ដា**

កាលពីថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ មន្ត្រីតំណាងធនាគារកណ្ដាលរវ៉ាន់ដាចំនួន ២ រូប បានមកទស្សនកិច្ចសិក្សាដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា និងចូលទស្សនានៅសារមន្ទីរព្រះស្រីល្បសានវន្តនៃ។ ទស្សនកិច្ចសិក្សានេះ ធ្វើឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ និងចំណេះដឹងពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ជាពិសេសការអភិវឌ្ឍប្រព័ន្ធបាគង ការគ្រប់គ្រងនិងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងការរៀបចំក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។



- **អាជ្ញាធររូបិយវត្ថុហុងកុង**

កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមការងារធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រុមការងាររបស់អាជ្ញាធររូបិយវត្ថុហុងកុង ដើម្បីរៀបចំវគ្គចែករំលែកចំណេះដឹងតាមប្រព័ន្ធអនឡាញជូនដល់មន្ត្រីធនាគារជាតិនៃកម្ពុជាចំនួន ៥០ រូប មកពីអគ្គនាយកដ្ឋានផ្សេងៗគ្នា រួមមាន អគ្គនាយកដ្ឋានប្រតិបត្តិការ អគ្គនាយកដ្ឋានបទប្បញ្ញត្តិនិងបរិយាបន្ន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គលេខាធិការដ្ឋាន

អគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ គោលបំណងនៃការរៀបចំវគ្គចែករំលែកចំណេះដឹងនេះ បានផ្តល់ឱកាសដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ទទួលបាននូវចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងការអភិវឌ្ឍ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ថ្មីៗរបស់អាជ្ញាធររូបិយវត្ថុហុងកុង និងធនាគារសម្រាប់ការទូទាត់អន្តរជាតិ ជាពិសេសស្វែងយល់ពីការវិវត្តនៃបច្ចេកវិទ្យាក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងសារៈសំខាន់ក្នុងការចូលរួមក្នុងគម្រោង mBridge និងគម្រោង Ensemble។

- **ក្របខណ្ឌអាស៊ាន**

ក្នុងក្របខណ្ឌអាស៊ាន បណ្តាធនាគារកណ្តាលក្នុងប្រទេសជាសមាជិកអាស៊ានបានចែករំលែកបទពិសោធន៍ ចំណេះដឹង វឌ្ឍនភាព បញ្ហាប្រឈម និងគំនិតផ្តួចផ្តើមថ្មីៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់។ ប្រធានបទដែលត្រូវបានលើកយកមកពិភាក្សាមានលក្ខណៈទូលំទូលាយ ដូចជាការពង្រឹងសុវត្ថិភាពនិងសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យា ការប្រយុទ្ធប្រឆាំងការឆបោកនិងការក្លែងបន្លំក្នុងការទូទាត់ យន្តការសម្របសម្រួលករណីឆបោកឆ្លងដែន ការពង្រឹងនីតិវិធីការកំណត់អត្តសញ្ញាណអតិថិជននិងការគ្រប់គ្រងហានិភ័យ ការអភិវឌ្ឍការទូទាត់ឆ្លងដែន ការតភ្ជាប់ខេអេចយូអរកូត និង P2P ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក និងការដោះស្រាយវិវាទនិងការការពារអតិថិជន ព្រមទាំងការពង្រឹងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

# ៦. ទិសដៅ

ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ សកម្មភាពពាណិជ្ជកម្ម លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងឆ្ពោះទៅរកសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជានឹងបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ស្របតាមនិន្នាការវិវត្តរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបន្តផ្តល់ការគាំទ្រ និងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកប្រព័ន្ធទូទាត់ និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការជំរុញឱ្យគ្រឹះស្ថានជាសមាជិកចូលរួមធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ឱ្យស្របតាមវឌ្ឍនភាពប្រព័ន្ធទូទាត់សងប្រាក់របស់ធនាគារជាតិនៃកម្ពុជា។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តជំរុញ និងលើកកម្ពស់ការទូទាត់តាមយ្យូអរកូត ដើម្បីពង្រីកការទូទាត់អន្តរប្រតិបត្តិការឱ្យកាន់តែទូលំទូលាយទាំងក្នុងប្រទេស និងជាមួយប្រទេសក្នុងតំបន់ ជាពិសេសគម្រោងទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែនទាំងទ្វេភាគី និងពហុភាគីជាមួយប្រទេស និងដៃគូសហការក្នុងតំបន់ និងអន្តរជាតិ។

ជាមួយនឹងការវិវត្តជាបន្តបន្ទាប់នៃសេវាទូទាត់បែបឌីជីថលនៅក្នុងប្រព័ន្ធធនាគារ និងប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងការត្រួតពិនិត្យជាប្រចាំចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីធានាការអនុលោមតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នសំដៅការពារផលប្រយោជន៍អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់។ ដើម្បីសម្រេចឱ្យបានទិសដៅទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួនបន្ថែមទៀត ដែលមានលក្ខណៈអំណោយផលដល់ការធ្វើពិពិធកម្មសេវាទូទាត់សងប្រាក់ ជំរុញគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចធ្វើការអភិវឌ្ឍសេវាទូទាត់សងប្រាក់បន្ថែមឱ្យកាន់តែសម្បូរបែប និងមានភាពទាក់ទាញ ដែលបម្រើជាប្រយោជន៍សម្រាប់អ្នកប្រើប្រាស់។ បទប្បញ្ញត្តិដែលនឹងដាក់ចេញនាពេលខាងមុខ ក៏យកចិត្តទុកដាក់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធានានូវភាពរឹងមាំ និងគ្រប់គ្រងនូវហានិភ័យនានាឱ្យមានប្រសិទ្ធភាព ក្នុងគោលដៅការពារសុវត្ថិភាពមូលនិធិរបស់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់។

ការត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយពិលាស ជាការងារស្នូលដែលត្រូវអនុវត្តយ៉ាងខ្ជាប់ខ្ជួន បន្ទាប់ពីការអភិវឌ្ឍនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់។ ក្រៅពីប្រព័ន្ធបាគងដែលត្រូវបានត្រួតពិនិត្យនិងវាយតម្លៃកាលពីឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើថ្នាលធនាគារជាតិនៃកម្ពុជា ដោយផ្អែកលើគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ដើម្បីធានាបាននូវសុវត្ថិភាព និងប្រសិទ្ធភាពរបស់ថ្នាលនេះ។ ស្របពេលជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការនិរន្តរភាព

សម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីធានាថាប្រព័ន្ធអាចបន្តដំណើរការពេលមានឧប្បត្តិហេតុណាមួយកើតឡើង។

ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ និងបន្តលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យស្របតាមផែនទីបង្ហាញផ្លូវអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានឹងបន្តសិក្សា និងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសមស្របថ្មីៗ ក៏ដូចជាបន្តធ្វើបច្ចុប្បន្នកម្មផែនទីបង្ហាញផ្លូវអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២៦-២០៣០។ លើសពីនេះ ក្នុងគោលបំណងជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅប្រទេសកម្ពុជាឱ្យកាន់តែទូលំទូលាយ ធនាគារជាតិនៃកម្ពុជានឹងបន្តរៀបចំក្របខណ្ឌ និងផែនការសកម្មភាពក្នុងការផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងចំណេះដឹងហិរញ្ញវត្ថុឌីជីថល ជាពិសេសការប្រើប្រាស់សេវាទូទាត់បាគងដល់មន្ត្រីពាក់ព័ន្ធ និស្សិត និងសាធារណជន។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ - ច្បាប់ និងបទប្បញ្ញត្តិ

| ល.រ | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១ | ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារនៃកម្ពុជា | ១៩៩៦ |
| ២ | ច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ | ១៩៩៧ |
| ៣ | ច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | ១៩៩៩ |
| ៤ | ច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០០៥ |
| ៥ | ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ | ២០០៦ |
| ៦ | ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ | ២០០៦ |
| ៧ | ប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ | ២០០៨ |
| ៨ | ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ | ២០០៨ |
| ៩ | ប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន | ២០១០ |
| ១០ | ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី | ២០១០ |
| ១១ | ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ | ២០១៤ |
| ១២ | សារាចរណែនាំស្តីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០១៦ |
| ១៣ | ប្រកាសស្តីពី សមាជិកភាពនៃប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៦ |
| ១៤ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ | ២០១៦ |
| ១៥ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៧ |
| ១៦ | ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៧ |
| ១៧ | សេចក្តីជូនដំណឹងស្តីពី កម្រៃប្រតិបត្តិការផ្ទេរប្រាក់សម្រាប់ "សេវាទូទាត់រហ័ស" | ២០១៧ |
| ១៨ | សេចក្តីជូនដំណឹងស្តីពី កម្រៃ សោហ៊ុយ និងការពិន័យសម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៧ |
| ១៩ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៨ |
| ២០ | សេចក្តីជូនដំណឹងស្តីពី ការកែសម្រួលគោលនយោបាយសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិរបស់សភាផាត់ទាត់ជាតិ | ២០១៨ |
| ២១ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធវីផែលផេ | ២០១៩ |
| ២២ | សេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ | ២០១៩ |

| ល.រ | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
| --- | --- | --- |
| ២៣ | សេចក្តីណែនាំស្តីពី កាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ២៤ | សេចក្តីណែនាំស្តីពី ការជ្រើសរើស និងការទទួលស្គាល់សួងការគណនេយ្យឯករាជ្យ ចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ២៥ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចឃ្យូអរកូត សម្រាប់ការទូទាត់សងប្រាក់ | ២០២០ |
| ២៦ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង | ២០២០ |
| ២៧ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង | ២០២០ |
| ២៨ | ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ | ២០២០ |
| ២៩ | ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធីប្រព័ន្ធរីធែលផេ | ២០២០ |
| ៣០ | ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ២០២០ |
| ៣១ | ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ២០២០ |
| ៣២ | សេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូខានស្វ៊ីច | ២០២០ |
| ៣៣ | សេចក្តីជូនដំណឹងស្តីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធខេមបូខានស្វ៊ីច | ២០២០ |
| ៣៤ | ឯកសារបាគង White Paper | ២០២០ |
| ៣៥ | សារាចរណែនាំស្តីពី នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២១ |
| ៣៦ | សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិក្នុងដំណាក់កាលសាកល្បង" | ២០២៣ |
| ៣៧ | សេចក្តីណែនាំស្តីពី ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២៤ |
| ៣៨ | សេចក្តីណែនាំស្តីពី ការកែសម្រួលបរិច្ឆេទ និងរយៈពេលបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០២៤ |
| ៣៩ | សេចក្តីណែនាំបន្ថែមស្តីពី ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២៤ |
| ៤០ | ប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ | ២០២៤ |
| ៤១ | សេចក្តីណែនាំស្តីពី ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការទូទាត់សងប្រាក់នៅកម្ពុជា និងប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែន | ២០២៥ |
| ៤២ | សេចក្តីណែនាំស្តីពី ការលើកកម្ពស់ការទូទាត់តាមខេអេចឃ្យូអរកូត សម្រាប់ពាណិជ្ជករ | ២០២៥ |
| ៤៣ | សេចក្តីជូនដំណឹងទៅគ្រឹះស្ថាន ស្តីពី កាតព្វកិច្ចក្នុងការបញ្ជូនរបាយការណ៍ពីកម្រៃសេវាលើការផ្ទេរប្រាក់អន្តរជាតិសម្រាប់អតិថិជនមកធនាគារជាតិនៃកម្ពុជា | ២០២៥ |
| ៤៤ | សេចក្តីណែនាំស្តីពី ការពង្រឹងនីតិវិធីនៃការជូនដំណឹងអំពីភាពរអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ជូនដល់សាធារណជន | ២០២៥ |

## ឧបសម្ព័ន្ធ ២ - បញ្ជីរាយនាមសមាជិកប្រព័ន្ធទូទាត់សងប្រាក់រួម

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការ ប្រព័ន្ធទូទាត់សងប្រាក់រួម | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការ ប្រព័ន្ធទូទាត់សងប្រាក់រួម |
|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២១ | ធនាគារ អូរៀនថល ម.ក |
| ២ | ធនាគារ រីង (ខេមបូឌា) ម.ក | ២២ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២៣ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៤ | ធនាគារ វឌ្ឍនៈ | ២៤ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | ២៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៦ | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | ២៦ | សាជីវកម្មធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់ |
| ៧ | ធនាគារ កាណាឌីយ៉ា ក.អ | ២៧ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៨ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ |
| ៩ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក | ២៩ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ |
| ១០ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី | ៣០ | ធនាគារ សាខម ប៊ែង ខេមបូឌា |
| ១១ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣១ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ១២ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ៣២ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក |
| ១៣ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ៣៣ | ធនាគារ អឹម ប៊ី (ខេមបូឌា) ម.ក |
| ១៤ | ធនាគារ ហត្ថា ម.ក | ៣៤ | ធនាគារ សហពាណិជ្ជ ក.អ |
| ១៥ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣៥ | ធនាគារ ឌីជីប៊ី ម.ក |
| ១៦ | ធនាគារ មេយប៊ែង (ខេមបូឌា) ម.ក | ៣៦ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ១៧ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក | ៣៧ | ធនាគារ អេ អឹម ខេ ភីអិលស៊ី |
| ១៨ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ៣៨ | ធនាគារ ខេប៊ីប្រាសាក់ ម.ក |
| ១៩ | ធនាគារ អេស ប៊ី អាយ លីហ្វរ ម.ក | ៣៩ | ធនាគារ ប៊ូយ៉ុងខ្មែរ |
| ២០ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក | ៤០ | ធនាគារពាណិជ្ជ អាល់ហ្វា ម.ក |

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការ ប្រព័ន្ធទូទាត់សងប្រាក់រួម | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការ ប្រព័ន្ធទូទាត់សងប្រាក់រួម |
|---|---|---|---|
| ៤១ | ធនាគារ អាយ ប៊ែង (ខេមបូឌា) ម.ក | ៤៩ | គ្រឹះស្ថាន លីហ្សរ ផេប្រ៊ូ ភីអិលស៊ី |
| ៤២ | ធនាគារ ស៊ីស៊ីយូ (កម្ពុជា) ភីអិលស៊ី | ៥០ | គ្រឹះស្ថានធានស្វ៊ិ អ៊ិនធើណេសិនណលថេកណូឡជី ម.ក |
| ៤៣ | ធនាគារ ភីក វេល ម.ក | ៥១ | គ្រឹះស្ថាន អេស៊ា យែស អិចប្រេស ម.ក |
| ៤៤ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ៥២ | គ្រឹះស្ថាន ផាយ ផេ ម.ក |
| ៤៥ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អម្រឹត ម.ក | ៥៣ | គ្រឹះស្ថាន បងឡួយ ផេមិុន ម.ក |
| ៤៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មហានគរ ម.ក | ៥៤ | គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក |
| ៤៧ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | ៥៥ | គ្រឹះស្ថាន យេស អ៊ិននើវេសិន ម.ក |
| ៤៨ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិុន សឺលូសិន ម.ក | ៥៦ | គ្រឹះស្ថាន តារាសាគរ ផេ ម.ក |

# ឧបសម្ព័ន្ធ ៣ - បញ្ជីរាយនាមគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់

**គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក**
អាគារលេខ ១៥ ផ្លូវលេខ ៣៩៧ ភូមិ៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
០១២ ៨១៥ ៧៣៨ / ០៩៦ ៨១៥ ៧៣៨៨
www.edeel.com

**គ្រឹះស្ថាន ស៊ីផែល ហ្វាយនែនសល សឺវីស ម.ក**
អាគារលេខ១៥៩ ផ្លូវលេខ៤៣២ ភូមិ៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
០១៨ ៨៨០០ ៨០០
www.bestmpay.com

**គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក**
អាគារ Keystone (No.146) ជាន់ទី១-២-៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៩៩ ៦៣៩
www.truemoney.com.kh

**គ្រឹះស្ថាន លី ហួរ ផេ ប្រូ ភីអិលស៊ី**
អគារលេខ ៧A ៩A និង១១A ផ្លូវ៥៩៨ ភូមិខ១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
០៨៧ ៦០១ ១១១
www.lyhourpay.com.kh

**គ្រឹះស្ថាន អាប៊ីត្រេរី ផេយ ម.ក**
Mei Lian Garden Hotel លេខ៣១៥ វិទ្យាលេខ១១៣ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០១០ ៣៧០ ៨៨៨

**គ្រឹះស្ថាន អាយផេ៨៨ (ខេមបូឌា) ម.ក**
ផ្ទះលេខ១៣ (ជាន់ទី២) មហាវិថីហ្សាលដឺហ្គោល (២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩០១ ៧៨៨
www.ipay88.com.kh

**គ្រឹះស្ថាន ផាយ ផេ ម.ក**
ផ្ទះលេខ២០ ផ្លូវ ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩៨៨ ៩៨៩ / ០៨៩ ៩៨៨ ៩៨៣
www.pipay.com

**គ្រឹះស្ថាន ធានស៊ូ អ៊ិនធើណេសិនណល ថេកណូឡូជី ម.ក**
អគារលេខ ៥៨-៥០ ជាន់ទី៣ ផ្លូវ ៣១០ ភូមិ ២ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០២៣ ៩៨៨ ៧៧៧
www.coolcashcam.com

**គ្រឹះស្ថាន បងឡួយ ផេមិន ម.ក**
ផ្ទះលេខ១០ ផ្លូវ២៨៨ ភូមិ៦ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០៨១ ៩៩៩ ៦១៨
www.bongloy.asia

**គ្រឹះស្ថាន អេស៊ា វៃលុយ អិចប្រេស ម.ក**
ផ្ទះលេខ B២-០៣៥-០៣៦ ផ្លូវកោះពេជ្រ (ស្ពានឥន្ទធនូ) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ៦៦៦ ៦៧៨ / ០៩៩ ៦៦៦ ៦៧៨ / ០៧១ ៦៦៦ ៦៧៨
www.asiaweiluy.com.kh

**គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិន សឺលូសិន ម.ក**
អគារលេខ២៣៩ (ROYAL K PLAZA) ជាន់ទី១៥ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០៧១ ៦៥៥ ៥៦៦៦ (១៥៦៨)
www.emoney.com.kh

**គ្រឹះស្ថាន ដាយនែមិក ផេមិន ម.ក**
អគារម៉េហ្គែន ជាន់ទី៦ បន្ទប់លេខ០២ និង០៣ ផ្លូវសុរកមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៩ ១៨៦ / ០២៣ ៩៨៩ ១៨២ / www.dynamic-payment.com

**គ្រឹះស្ថាន តារាសាគរ ផេ ម.ក**
ប្លុក៧៣ ជាន់ផ្ទាល់ដី អគារលេខ២ Phnom Penh City Center ផ្លូវ៦៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៩៣ ៩៣៩ ៩៧៧
www.darasakorpay.com

**គ្រឹះស្ថាន អេលីមិន ផេមិន សូលូសិន (ខេមបូឌា) ម.ក**
ផ្លូវលេខB១៨ ផ្លូវបេតុង ភូមិ០១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៨៦ ៦៨៨ ៨៩៥

**គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក**
ផ្ទះលេខ៥៤B (ជាន់ផ្ទាល់ដី និងជាន់ទី១) ផ្លូវ ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៩៥៥ ៥៥៥៦

**គ្រឹះស្ថាន ផារ៉ាហ្គន ផេមិន ស៊ីវីស ម.ក**
អាគារលេខ២១៦ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១២ ៩៥៦ ២៣៧

**គ្រឹះស្ថាន ឃេស អ៊ិនណើវេសិន ម.ក**
អាគារលេខ១០៥ ជាន់ទី៤ ផ្លូវ ១៩៨៤A សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០៧០ ២២២ ៧០៣
www.kessinnovation.io

**គ្រឹះស្ថាន វ័ន ផេ ម.ក**
ផ្ទះលេខអេ១១ ផ្លូវលេខ២១០ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
០៩៩ ២៣៣ ២៣៣/ ០១១ ៦០០ ១១១
www.onepay.com.kh

**គ្រឹះស្ថាន លីន ផេ ផេមិន ស៊ីលូសិន ម.ក**
ផ្ទះលេខ ៩០ ៩២ និង៩៤ ជាន់ទី១ (E-1) ផ្លូវលេខ ២១៧ សង្កាត់អូឫស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ២៣៨ ០៣០ / ០៩៦ ៦៧៥ ៣៥៥៤
www.lync-pay.com

**គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក**
អាគារលេខ១ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨១ ៩៧៨ ៨៨៩ / ០៨៥ ៩៧៨ ៨៨៩
www.u-pay.com

**គ្រឹះស្ថាន ស្ដារផេ ហ្វីនថេក ម.ក**
ដីឡូត៍លេខ២៧៨៧ ភូមិទួលក្រសាំង ឃុំកោខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល
០៨១ ៩១៦ ១០៩

**គ្រឹះស្ថាន ឡានតុន អ៊ិនធើណេសិនណល (ខេមបូឌា) ផេមិន ស៊ីវីស ម.ក**
អគារ Morgan Tower យ៉ូនីត ០១/០២/០៣ ជាន់ទី២០ ផ្លូវសុភមង្គល (កោះពេជ្រ) ភូមិ១៤
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩០០ ០៩១
www.lantonpay.com

**គ្រឹះស្ថាន សាន់ផេ (ខេមបូឌា) ម.ក**
អាគារ Morgan Tower, Unit 7/8a/8b, ជាន់ទី២០ ផ្លូវសុភមង្គល (កោះពេជ្រ) ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៦៧៨ ២៦៧៨
www.sunpay.com.kh

**គ្រឹះស្ថាន គ្លីក ផេម៉ិន (ខេមបូឌា) ម.ក**
DK Santuary លេខ ១២៨ EF ជាន់ទី៤ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១០ ៩២៧ ៤៥០

**គ្រឹះស្ថាន កៃ ហ្វូ តុង ផេម៉ិន ម.ក**
សណ្ឋាគារប្លាទីនអន្តរជាតិ ផ្លូវប៉ូឡូវៃ ជាន់ទី ១ និងទី២ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
០៩៧ ៧០១ ៦៨៨៣ / ០៩៣ ៩២២ ២២៩
www.cpay168.com

**គ្រឹះស្ថាន ផេយ៉ុន ម.ក**
លេខ ៣F មជ្ឈមណ្ឌល PGCT ផ្លូវលេខ ២៧៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៧ ៤៧៥
www.payon.com.kh

**គ្រឹះស្ថាន ជីន ហុង ជិន ថេកណូឡូជី ម.ក**
ផ្លូវ ២ធ្នូ ភូមិ ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
០៨៨ ៣២៣ ១១៨៨៨ / ០៨៨ ៣៣២ ៣៨៨៨
www.dvpay.com

**គ្រឹះស្ថាន ផេនទ័រ (ខេមបូឌា) ម.ក**
អគារលេខ៦៨៥ ជាន់ទី១-២ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០២៣ ៩០២ ២៤៤ / ០៨៦ ៨២១ ៨៨៨
www.pentorcambodia.com.kh

**គ្រឹះស្ថាន យ៉ុង ស៊ីន ផេ ម.ក**
អគារលេខ៨៦ ផ្លូវលេខ២១៤ ភូមិ២ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ
០៩៦ ៨៦៦ ៦០៩៩

**គ្រឹះស្ថាន អេច ផេ ស៊ីវីស ម.ក**
អគារ One Park លេខA-១៩/២០ ផ្លូវR៨ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០១៨ ២៨២ ៨៣៧៥

# ឧបសម្ព័ន្ធ ៤ - បញ្ជីរាយនាមគ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក

## ១. គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២២ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ២ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២៣ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក |
| ៣ | ធនាគារ អាយ ប៊ែង (ខេមបូឌា) ម.ក | ២៤ | ធនាគារ ហ្វីលីព ភីអិលស៊ី |
| ៤ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | ២៥ | ធនាគារ ព្រីនស៍ ម.ក |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៧ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | ២៨ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៩ | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ៣០ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣១ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ |
| ១១ | សាជីវកម្មធនាគារ កាថេ យូណៃធីត (កម្ពុជា) ចំកាត់ | ៣២ | ធនាគារ សហពាណិជ្ជ ក.អ |
| ១២ | ធនាគារ ពាណិជ្ជទីមួយ | ៣៣ | ធនាគារ វឌ្ឍនៈ |
| ១៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣៤ | ធនាគារ ឌីជីប៊ី ម.ក |
| ១៤ | ធនាគារ ហត្ថា ម.ក | ៣៥ | ធនាគារ អូរៀនថល ម.ក |
| ១៥ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣៦ | សាខាធនាគារកសិកន ផាប់ប្លឹក ខមភេនី លីមីធីត (ភ្នំពេញ) |
| ១៦ | សាខាធនាគារ អ៊ិនដាសស្ទៀល ប៊ែង អហ្វ ខូរៀ ភ្នំពេញ | ៣៧ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៧ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៨ | ធនាគារ អូរី (ខេមបូឌា) ម.ក |
| ១៨ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | ៣៩ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ១៩ | ធនាគារ ខេប៊ីប្រាសាក់ ម.ក | ៤០ | ធនាគារ អេចអេច (ខេបូឌា) ម.ក |
| ២០ | ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមមើសល ប៊ែង ខូអិលធីឌី សាខាភ្នំពេញ | ៤១ | ធនាគារ អេស ប៊ី អាយ លីហ្សូ ម.ក |
| ២១ | ធនាគារ មីហ្សូហូ អិលធីឌី | ៤២ | ធនាគារ បាងកក មហាជនទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា |

## ២. គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២៣ | ធនាគារ អេស ប៊ី អាយ លីហ្វូរ ម.ក |
| ២ | ធនាគារ អាយ ប៉ែង (ខេមបូឌា) ម.ក | ២៤ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ៣ | ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | ២៥ | ធនាគារ សហពាណិជ្ជ ក.អ |
| ៤ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | ២៦ | ធនាគារ វឌ្ឍនៈ |
| ៥ | ធនាគារ ប្រេដ ប៉ែង (ខេមបូឌា) ភីអិលស៊ី | ២៧ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៨ | ធនាគារ ឌីជីប៊ី ម.ក |
| ៧ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ២៩ | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៉ែង ម.ក | ៣០ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ៣១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣២ | ធនាគារ អូរៀនថល ម.ក |
| ១១ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣៣ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ១២ | ធនាគារ ហត្ថា ម.ក | ៣៤ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក |
| ១៣ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣៥ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ១៤ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៦ | ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក |
| ១៥ | ធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី | ៣៧ | ធនាគារ ស៊ីស៊ីយូ ខមមើសល ប៉ែង ម.ក |
| ១៦ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | ៣៨ | ធនាគារ ប្រ៊ីដ ម.ក |
| ១៧ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣៩ | ធនាគារ ផេនដា ខមមើសល ប៉ែង ម.ក |
| ១៨ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | ៤០ | ធនាគារ ខេប៊ីប្រាសាក់ ម.ក |
| ១៩ | ធនាគារ ព្រីនស៍ ម.ក | ៤១ | ធនាគារ ភីក វេល ម.ក |
| ២០ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក | ៤២ | ធនាគារ អេចអេច (ខេមបូឌា) ម.ក |
| ២១ | ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី | ៤៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ម.ក |
| ២២ | ធនាគារ ស្ថាបនា ភីអិលស៊ី | | |



IPS

KHQR